ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
General Directorate of Rubber

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅ
# អនុវត្តការងារឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកៅស៊ូ



# មាតិកា

**១. សេចក្តីផ្តើម**..........១
១.១ ប្រវត្តិកៅស៊ូធម្មជាតិ..........១
១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ..........២
១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៨..........២
១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៩..........៣
១.៤.១ ការប្រើប្រាស់កៅស៊ូធម្មជាតិ..........៣
១.៤.២ បរិមាណការផលិតកៅស៊ូធម្មជាតិ..........៣
១.៤.៣ តម្លៃកៅស៊ូនិងប្រេង..........៤
**២. លទ្ធផលការងារសំខាន់ៗក្នុងឆ្នាំ២០១៨**..........៤
២.១ ការងាររដ្ឋបាលនិងនីតិកម្ម..........៤
២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក..........៤
២.១.២ ការងារនីតិកម្ម..........៥
២.១.៣ ការងារផ្សព្វផ្សាយ បណ្តុះបណ្តាល និងសិក្ខាសាលា..........៦
២.២ ការងារផែនការនិងហិរញ្ញវត្ថុ..........៨
២.២.១ ការងារផែនការ..........៨
២.២.២ ការងារហិរញ្ញវត្ថុ..........៩
២.៣ ការងារអភិវឌ្ឍន៍..........១១
២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ..........១១
២.៣.២ ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ..........១៤
២.៤ ការងារពិសោធន៍និងស្រាវជ្រាវ..........១៥
២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ..........១៧
២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)..........១៧
២.៥.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)..........១៩
២.៥.៣ កិច្ចសហប្រតិបត្តិការជាមួយ CIRAD..........១៩
២.៥.៤ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)..........១៩
២.៥.៥ អង្គការស្បៀងអាហារនិងកសិកម្ម (FAO)..........២០
២.៥.៦ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន..........២០
២.៥.៧ កិច្ចសហប្រតិបត្តិការជាមួយ CATAS..........២១
២.៥.៨ ការរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និងវៀតណាម (CLV-DTA)..........២១
**៣. បញ្ហាប្រឈម**..........២១
**៤. សំណូមពរ**..........២២
**៥. សន្និដ្ឋាន**..........២៣
**៦. ទិសដៅអនុវត្តការងារឆ្នាំ២០១៩**..........២៣

# តារាង


តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ ..... ៥
តារាងទី២ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៨ (ហិកតា) ..... ១២
តារាងទី៣ កម្មវិធីសន្និសីទកិច្ចប្រជុំនិងសន្និបាតប្រចាំឆ្នាំ២០១៨ របស់ ANRPC ..... ១៨
តារាងទី៤ ព្រឹត្តិការណ៍សំខាន់របស់ ANRPC ក្នុងឆ្នាំ២០១៩ ..... ១៨


# ដ្យាក្រាម


ដ្យាក្រាមទី១ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០១៧និង២០១៨ ..... ១០
ដ្យាក្រាមទី២ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៨ ..... ១១
ដ្យាក្រាមទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៨ (%) ..... ១២
ដ្យាក្រាមទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៤-២០១៨ (ហិកតា) ..... ១២
ដ្យាក្រាមទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំនិងសរុបឆ្នាំ២០១៤-២០១៨ (ហិកតា) ..... ១៣
ដ្យាក្រាមទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១៣-២០១៨ ..... ១៤
ដ្យាក្រាមទី៧ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ និងឈើកៅស៊ូឆ្នាំ២០១៣-២០១៨ ..... ១៤
ដ្យាក្រាមទី៨ អត្រាគុណភាពផលិតផលកៅស៊ូ២០១៣-២០១៨ ..... ១៥


# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ ..... ២៥
ឧបសម្ព័ន្ធទី២ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨ ..... ២៦
ឧបសម្ព័ន្ធទី៣ គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៩ ..... ២៩
ឧបសម្ព័ន្ធទី៤ ស្ថិតិ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ១៩៨០-២០១៨ ..... ៣២
ឧបសម្ព័ន្ធទី៥ ស្ថានភាពការងារអាជីវកម្ម ផលិតកម្ម និងនីហរ័ណកម្មកៅស៊ូឆ្នាំ២០១៨ ..... ៣៣
ឧបសម្ព័ន្ធទី៦ ស្ថិតិដំណាំកៅស៊ូឆ្នាំ២០១៨ ..... ៣៤
ឧបសម្ព័ន្ធទី៧ ស្ថិតិផ្ទៃដីកៅស៊ូសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៨ ..... ៣៨
ឧបសម្ព័ន្ធទី៨ ស្ថិតិផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋនិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(វសកក)ឆ្នាំ២០១៨ ..... ៤២
ឧបសម្ព័ន្ធទី៩ ស្ថិតិផ្ទៃដីដាំដុះកៅស៊ូតាមឆ្នាំនីមួយៗគិតត្រឹមឆ្នាំ២០១៨ ..... ៤៣
ឧបសម្ព័ន្ធទី១០ ស្ថិតិផ្ទៃដីកៅស៊ូគ្រួសារឆ្នាំ២០១៨ ..... ៤៨
ឧបសម្ព័ន្ធទី១១ ស្ថិតិផ្ទៃដីកៅស៊ូលម្អិតតាមខេត្តឆ្នាំ២០១៨ ..... ៤៩
ឧបសម្ព័ន្ធទី១២ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលម្ចាស់វិនិយោគក្នុងស្រុកនិងបរទេសលើដំណាំកៅស៊ូឆ្នាំ២០១៨ ..... ៥៤
ឧបសម្ព័ន្ធទី១៣ ស្ថិតិផលិតផលនិងការនាំចេញកៅស៊ូធម្មជាតិពីឆ្នាំ២០០៧ ដល់ ២០១៨ ..... ៥៥
ឧបសម្ព័ន្ធទី១៤ ស្ថិតិផ្ទៃដីកៅស៊ូធម្មជាតិពីឆ្នាំ២០០៧ ដល់ ២០១៨ ..... ៥៦
ឧបសម្ព័ន្ធទី១៥ តារាងរោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ និងឈើកៅស៊ូនៅក្នុងឆ្នាំ២០១៨ ..... ៥៧
ឧបសម្ព័ន្ធទី១៦ ចំណូលថវិការដ្ឋឆ្នាំ២០១៨ ..... ៥៩

# បទបង្ហាញ

លទ្ធផលការងារឆ្នាំ២០១៨និងលើកទិសដៅអនុវត្តការងារឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកៅស៊ូ.................. ៦០

# រូបថត

១. រូបថតស្តីពីសកម្មភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូនិងថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ...៧០
២. រូបថតស្តីពីសកម្មភាពនាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម.....................................................................៧២
៣. រូបថតស្តីពីសកម្មភាពនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ........................................................................ ៧៣
៤. រូបថតស្តីពីសកម្មភាពនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ...........................................................៧៤
៥. រូបថតស្តីពីសកម្មភាពនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ .................................................................៧៥
៦. រូបថតស្តីពីសកម្មភាពនាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ ................................................៧៦
៧. រូបថតស្តីពីសកម្មភាពវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ....................................................................៧៧

# ឯកសារយោង

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារឆ្នាំ២០១៨និងលើកទិសដៅអនុវត្តការងារ ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកៅស៊ូ

## ១. សេចក្តីផ្តើម
### ១.១ ប្រវត្តិកៅស៊ូធម្មជាតិ

១- ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយលោក **ប៊ូ យ៉ា** ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្ន ខេត្តព្រះសីហនុ) លើផ្ទៃដីជាង១៥០ហិកតា។ មកដល់ឆ្នាំ១៩២១ ទើបដំណាំកៅស៊ូមានលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ដែលបានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥ នៅលើដីក្រហមបាសាល់នៅខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង ៥០.០០០ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីជាង៦៨.០០០ហិកតា ក្នុងនោះផ្ទៃដីចៀរមានជាង៣៩.០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូជាង៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។ នៅជំនាន់នោះកម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ច្បាស់ថាជាប្រទេសដែលមានចម្ការកៅស៊ូល្អ មានទិន្នផលនិងផលិតផលកៅស៊ូប្រកបដោយគុណភាពខ្ពស់នៅក្នុងតំបន់អាស៊ី។

២- ចាប់តាំងពីឆ្នាំ១៩៧០មក ដោយសារសង្គ្រាមក្នុងស្រុក ជាពិសេសដំណាក់កាលចុងក្រោយស្ថិតក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហម រាល់ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យត្រូវបានបំផ្លាញស្ទើរដល់ឫសគល់ រហូតដល់អាយុជីវិតប្រជាជនរាប់លាននាក់ត្រូវបានទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ និងស្ថានភាពចម្ការកៅស៊ូត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរ រីឯជីវិតកម្មកររាប់ពាន់នាក់ក៏ត្រូវបានសម្លាប់។

៣- ចាប់ពីឆ្នាំ១៩៨០ រដ្ឋាភិបាលបានរៀបចំដាក់ឱ្យដំណើរការស្តារនិងធ្វើអាជីវកម្មចម្ការកៅស៊ូចាស់ៗដែលនៅសេសសល់ឡើងវិញ រហូតមកដល់បច្ចុប្បន្ន និងបានដាក់ចេញនូវសេចក្តីប្រកាសស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ព្រមទាំងបានផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុកនិងបរទេស ក្នុងគោលបំណងប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតករកៅស៊ូដ៏មានសក្តានុពលនៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយចំណែក ចូលទៅក្នុងទីផ្សារពិភពលោក។ រហូតមកដល់បច្ចុប្បន្ននេះ ដំណាំកៅស៊ូនៅតែត្រូវបានគេប្រសិទ្ធនាមថាជា "**មាសស**" និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ខ្ពស់បន្ទាប់ពីផលិតកម្មស្រូវ។ ជាពិសេសចាប់តាំងពីឆ្នាំ១៩៩៣ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់អតីតចម្ការកៅស៊ូរដ្ឋទាំង៧ ជាបន្តបន្ទាប់ពីស្វ័យភិបាលសេដ្ឋកិច្ច មកជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និងចុងក្រោយបានធ្វើអវិនិយោគឱ្យទៅផ្នែកឯកជនគ្រប់គ្រងទាំងស្រុងក្នុងអំឡុងឆ្នាំ២០០៨-២០០៩។ ទន្ទឹមនឹងការធ្វើឯកជនភាវូបនីយកម្មអតីតចម្ការកៅស៊ូរដ្ឋ តម្លៃកៅស៊ូបានកើនឡើងខ្ពស់ជាបន្តបន្ទាប់ និងស្របពេលដែលរាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់វិនិយោគិនក្នុងស្រុកនិងបរទេស បានជំរុញឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាទាំងចម្ការកសិឧស្សាហកម្មនិងចម្ការកៅស៊ូគ្រួសារ បានចាប់ផ្តើមបង្កើនសន្ទុះនិងមានការវិវឌ្ឍមួយប្រកបដោយថាមភាពទាំងនៅក្នុងផ្នែកដាំដុះ ការយកផល និងការនាំចេញ ផលិតផលកៅស៊ូផងដែរ។

## ១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ

៤- កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចមួយប្រភេទដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនិងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្តល់ជាវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម ផលិតជាមុខទំនិញរាប់ពាន់មុខសម្រាប់បម្រើតម្រូវការប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ សំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន ក្នុងផ្នែកវេជ្ជសាស្ត្រ (ស្រោមដៃពេទ្យ ស្រោមអនាម័យ។ល។) និងប្រើជាកំណល់សំណង់អាគារ ផ្លូវថ្នល់ និងស្ពានធំៗ ទប់ទល់ការជួលរលំដោយសាររញ្ជួយផែនដី។ល។ ផ្តល់ឈើសម្រាប់ប្រើប្រាស់សំណង់ ផលិតគ្រឿងសង្ហារឹម ជាឈើតន្នៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតងឡើងវិញ ដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថានដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាពិភពលោកសំខាន់មួយក្នុងពេលបច្ចុប្បន្ន។

## ១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៨

៥- រយៈពេល១១ខែក្នុងឆ្នាំ២០១៨នេះ ផលិតផលកៅស៊ូធម្មជាតិពិភពលោកត្រូវបានកត់ត្រាថាមានចំនួន១២,៨១៦លានតោន បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ដែលមានចំនួន១២,១៥៦លានតោន មានកំណើន៦៦០.០០០តោន ស្មើនឹង៥,៤%។ តួលេខនេះក៏បានរួមបញ្ចូលទាំងផលិតផលកៅស៊ូធម្មជាតិពីបណ្តាប្រទេសមិនមែនជាសមាជិករបស់ ANRPC ផងដែរ។ ក្នុងអំឡុងពេលនេះ ថ្វីបើផលិតកម្មកៅស៊ូក្នុងបណ្តាប្រទេសជាសមាជិករបស់ ANRPC មានកំណើន៤,៦% ប៉ុន្តែផលិតកម្មកៅស៊ូក្នុងប្រទេសជាសមាជិកមួយចំនួនបានធ្លាក់ចុះ ដូចជាប្រទេសវៀតណាម (០,៥%) ម៉ាឡេស៊ី (១៨,៧%) ឥណ្ឌា (៩,១%) និងស្រីលង្កា (២,៩%)។ យោងតាមការធ្វើបច្ចុប្បន្នភាពបឋមនៅខែវិច្ឆិកាឆ្នាំ២០១៨ ផលិតកម្មកៅស៊ូធម្មជាតិប្រចាំឆ្នាំ ត្រូវបានគេរំពឹងថានឹងកើនឡើង៤,៥% ដែលមានបរិមាណរហូតដល់១៣,៩៥២លានតោនក្នុងឆ្នាំ២០១៨ (ANRPC Nov, 2018)។

៦- តម្រូវការកៅស៊ូធម្មជាតិពិភពលោកបានកើនឡើងដល់១២,៨៥២លានតោន ស្មើនឹងកំណើនកើនឡើង៥% ក្នុងអំឡុងពេល១១ខែក្នុងឆ្នាំ២០១៨។ បណ្តាប្រទេសជាសមាជិករបស់ ANRPC បានបង្ហាញពីតម្រូវការកើនឡើង៦,៥% មានបរិមាណចំនួន៨,៤៣៨លានតោន។ ក្នុងរយៈពេលនេះ បណ្តាប្រទេសមិនមែនជាសមាជិករបស់ ANRPC មានអត្រាកំណើនយឺតត្រឹម២,២% ដែលមានចំនួន៤,៤១៤លានតោន។ ការប្រើប្រាស់កៅស៊ូធម្មជាតិដោយប្រទេសធំៗពីរក្នុងចំណោមប្រទេសជាសមាជិករបស់ ANRPC គឺប្រទេសចិន និងឥណ្ឌាមានបរិមាណជិត៥០% នៃតម្រូវការពិភពលោក។ កំណើនតម្រូវការកៅស៊ូធម្មជាតិពិភពលោកនៅឆ្នាំ២០១៨ ត្រូវបានកែតម្រូវថយចុះនៅត្រឹម៥,២% មានបរិមាណ១៤,០១៧លានតោន ធៀបនឹងឆ្នាំមុន (ANRPC Nov,2018)។

៧- ផ្អែកតាមទិន្នន័យបានបង្ហាញថា បរិមាណផ្គត់ផ្គង់នឹងតិចជាងតម្រូវការចំនួន៦៥.០០០តោន នៅក្នុងឆ្នាំ២០១៨ ដែលអតុល្យភាពរវាងតម្រូវការនិងការផ្គត់ផ្គង់ មិនអាស្រ័យលើស្ថានភាពអំណោយផលនៃទីផ្សារទិញ-លក់ភ្លាមៗ និងទីផ្សារជួញដូរតាមកិច្ចសន្យាទេ ដែលទីផ្សារទាំងនេះទំនងជាទទួលរងឥទ្ធិពលពីកត្តាខាងក្រៅច្រើនជាង រួមមាន៖ សំណល់សន្និធិកៅស៊ូច្រើននៅក្នុងឃ្លាំងនានានៃទីផ្សារក្រុងសៀងហៃ និងនៅមជ្ឈមណ្ឌល

ពាណិជ្ជកម្មសេរីក្រុងក្វាងទុង ស្ថានភាពវិវឌ្ឍនៃឧស្សាហកម្មប្រេងឆៅ និងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងប្រទេសចិន ដែលហេតុការណ៍នេះ បានធ្វើឱ្យស្រុតចុះរំញោចទីផ្សារកៅស៊ូទិញ-លក់ភ្លាមៗ (ANRPC Nov,2018)។

## ១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៩

### ១.៤.១ ការប្រើប្រាស់កៅស៊ូធម្មជាតិ

៨- ការប្រើប្រាស់កៅស៊ូធម្មជាតិនៅក្នុងប្រទេសចិនមានប្រមាណ៤០% នៃការប្រើប្រាស់នៅលើពិភពលោក ត្រូវបានព្យាករថានឹងធ្លាក់ចុះ មានបរិមាណតែ៥,៨៥លានតោន គឺកើនត្រឹមតែ៣,២% ក្នុងឆ្នាំ២០១៩ ធៀបនឹងកំណើនប៉ាន់ប្រមាណបឋមស្មើនឹង៥,៣% ក្នុងឆ្នាំ២០១៨ និង៧,៥% ក្នុងឆ្នាំ២០១៧។

៩- នៅប្រទេសឥណ្ឌាការប្រើប្រាស់កៅស៊ូធម្មជាតិទំនងជានឹងធ្លាក់ចុះដល់៤% នៅឆ្នាំ២០១៩។ តាមការប៉ាន់ប្រមាណដំបូងប្រទេសឥណ្ឌាបានប្រើប្រាស់កៅស៊ូធម្មជាតិប្រមាណ១,២១៨លានតោន នៅឆ្នាំ២០១៨ ដែលកើនឡើង១២,៦% ធៀបនឹងឆ្នាំមុន ភាគច្រើនជាតម្រូវការខ្ពស់ពីផ្នែករថយន្តធុនធ្ងន់។ នៅឆ្នាំ២០១៨ ការប្រើប្រាស់កៅស៊ូធម្មជាតិរបស់ប្រទេសនេះមានប្រមាណ៩% នៃការប្រើប្រាស់ពិភពលោក។

### ១.៤.២ បរិមាណការផលិតកៅស៊ូធម្មជាតិ

១០- តាមការប៉ាន់ប្រមាណបឋម នៅក្នុងឆ្នាំ២០១៩ ផលិតកម្មកៅស៊ូធម្មជាតិពិភពលោកទំនងជានឹងកើនឡើងរហូតដល់៦,៦% មានបរិមាណ១៤,៨៨៤លានតោន ធៀបទៅនឹងឆ្នាំ២០១៨ មានកំណើនត្រឹមតែ៤,៤%។ ដោយហេតុថា ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១២ កសិករបានសម្រុកដាំកៅស៊ូយ៉ាងច្រើនក្នុងរយៈពេល៧ឆ្នាំមុននេះ ដោយសារតម្លៃកៅស៊ូខ្ពស់ដែលមិនធ្លាប់មានពីមុនមក និងមួយផ្នែកនៃផ្ទៃដីទាំងនោះត្រូវបានគេរំពឹងថានឹងត្រូវបានបើកចៀរនៅឆ្នាំ២០១៩។

១១- ផលិតកម្មកៅស៊ូនៅប្រទេសថៃទំនងជានឹងកើនឡើង៦,៦% មានបរិមាណ៥,៣៥៣លានតោន នៅឆ្នាំ២០១៩ ធៀបទៅនឹងឆ្នាំ២០១៨ មានកំណើន៨,៨% (ការប៉ាន់ប្រមាណបឋម)។ បច្ចុប្បន្ន ផលិតកម្មកៅស៊ូធម្មជាតិពិភពលោក បានមកពីប្រទេសថៃមានប្រមាណ៣៥%។ ក្នុងឆ្នាំ២០១៨ ផលិតកម្មកៅស៊ូរបស់ប្រទេសឥណ្ឌាបានធ្លាក់ចុះប្រមាណ៩,៥% មានបរិមាណ៦៤៥.០០០តោន ដោយសារទឹកជំនន់នៅ Kerala (Key grower, 2018) ជំងឺស្លឹកបានរាតត្បាតនិងដីមានគុណភាពខ្សោយ និងផ្ទៃដីកៅស៊ូពេញវ័យប្រមាណ១៩០.០០០ហិកតាមិនត្រូវបានចៀរកាលពីឆ្នាំមុន ដោយសារតម្លៃកៅស៊ូមិនអំណោយផល។ តាមការសន្មត់ផលិតកម្មកៅស៊ូរបស់ប្រទេសឥណ្ឌា ត្រូវបានគេរំពឹងថានឹងកើនឡើងវិញប្រមាណ១០% នៅឆ្នាំ២០១៩ បើលក្ខខណ្ឌអាកាសធាតុធម្មតា។

១២- ទោះបីជាផលិតកម្មកៅស៊ូធម្មជាតិពិភពលោកដែលបានរំពឹងទុកជាមុន មានបរិមាណ១៤,៨៤៤លានតោន និងការប្រើប្រាស់នៅលើពិភពលោក មានចំនួន១៤,៥៩០លានតោន ស្ទើរតែប្រហាក់ប្រហែលគ្នាក៏ដោយ ប៉ុន្តែមូលដ្ឋានគ្រឹះនៃទីផ្សារទំនងជានៅតែមិនល្អប្រសើរពេញមួយឆ្នាំ២០១៩។

១៣- ក្នុងករណីដែលតម្លៃកៅស៊ូធម្មជាតិត្រូវបានស្តារឡើងវិញ ក្នុងឆ្នាំ២០១៩ផលិតកម្មកៅស៊ូធម្មជាតិប្រទេសថៃអាចមានអត្រា១៤% ប្រទេសម៉ាឡេស៊ី៥៣% និងប្រទេសឥណ្ឌា៦៥% បន្ថែមទៀតលើសពីការរំពឹងទុក។

### ១.៤.៣ តម្លៃកៅស៊ូនិងប្រេង

១៤- ទីផ្សារកៅស៊ូធម្មជាតិត្រូវបានរងឥទ្ធិពលដោយកត្តាខាងក្រៅមួយចំនួន ដូចមុខទំនិញអាស៊ីផ្សេងៗទៀត ដែលមានទំនាក់ទំនងអវិជ្ជមានជាមួយប្រាក់ដុល្លារអាម៉េរិក។ ហេតុនេះហើយ ភាពខ្លាំងនៃប្រាក់ដុល្លារអាម៉េរិក បានដាក់សម្ពាធទៅដល់ទីផ្សារកៅស៊ូធម្មជាតិ ដោយសារតែធនាគារកណ្តាលសហព័ន្ធអាម៉េរិក គ្រោងនឹងកែលម្អអត្រាការប្រាក់គោលនយោបាយ២លើកបន្ថែមទៀតក្នុងឆ្នាំ២០១៩ នាំឱ្យប្រាក់ដុល្លារអាម៉េរិកនៅតែរឹងមាំ ដែលមិនអំណោយផលដល់តម្លៃកៅស៊ូធម្មជាតិឡើយ។

១៥- ទស្សនវិស័យសេដ្ឋកិច្ចពិភពលោកដែលរំពឹងទុកចំពោះទីផ្សារប្រេងឆៅ មិនអំណោយផលដល់ការងើបឡើងវិញនៃតម្លៃកៅស៊ូធម្មជាតិនៅឆ្នាំ២០១៩ទេ ពីព្រោះទីផ្សារកៅស៊ូធម្មជាតិជាធម្មតាមានសហសម្ព័ន្ធជាលក្ខណៈវិជ្ជមាន (Positive correlation) ជាមួយនឹងទីផ្សារប្រេងឆៅ។ យោងតាមរបាយការណ៍ថាមពលដែលបានចេញផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ដោយរដ្ឋបាលព័ត៌មានថាមពលអាម៉េរិក ប្រេងឆៅ Brent ត្រូវបានរំពឹងថានឹងមានតម្លៃជាមធ្យម៦១ដុល្លារក្នុងមួយបារ៉ែលក្នុងឆ្នាំ២០១៩ ទាបជាងការប៉ាន់ប្រមាណបឋមក្នុងឆ្នាំ ២០១៨ ដែលមានតម្លៃមធ្យម៧១,៤០ដុល្លារក្នុងមួយបារ៉ែល។

១៦- ផ្អែកលើនិន្នាការសេដ្ឋកិច្ចពិភពលោកដែលកំពុងលេចឡើង កត្តាមូលដ្ឋាន (តម្រូវការនិងការផ្គត់ផ្គង់) កត្តារូបិយប័ណ្ណ និងការប្រមើលអនាគតនៃប្រេងឆៅបង្ហាញថា ក្នុងឆ្នាំ២០១៩តម្លៃកៅស៊ូធម្មជាតិមិនអាចមានលទ្ធភាពងើបឡើងវិញបានទេ។

## ២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០១៨

ក្នុងឆ្នាំ២០១៨កន្លងទៅ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងយ៉ាងសកម្ម ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

### ២.១ ការងាររដ្ឋបាលនិងនីតិកម្ម

### ២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក

១៧- អនុក្រឹត្យលេខ១៨៨អនក្រ.បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូមានបេសកកម្មធានាការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម កាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាដល់ការប្រកួតប្រជែងនៅលើទីផ្សារ តាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍនិងការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម អាជីវកម្មកែច្នៃសំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ។

១៨- អគ្គនាយកដ្ឋានកៅស៊ូ មានភារកិច្ចជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារជាអាទិ៍៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ ចក្ខុវិស័យ គោលដៅ បេសកកម្ម និងកម្មវិធីអភិវឌ្ឍន៍អនុវិស័យកៅស៊ូនៅកម្ពុជា សម្រាប់រយៈពេលមធ្យមនិងវែង កសាងមូលដ្ឋានគតិយុត្ត លិខិតបទដ្ឋានច្បាប់ ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍកៅស៊ូធានារាល់ដំណើរការផ្សេងៗទៀត ដែលមានការពាក់ព័ន្ធដល់អនុវិស័យកៅស៊ូទូទាំងប្រទេស ព្រមទាំងភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

១៩- អគ្គនាយកដ្ឋានកៅស៊ូ មាននាយកដ្ឋានជំនាញចំនួន៥ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន១ ជាសេនា-

ផិការក្នុងការបំពេញភារកិច្ចទទួលខុសត្រូវតាមជំនាញ សំដៅអភិវឌ្ឍន៍អនុវិស័យកៅស៊ូនៅទូទាំងប្រទេស (ឧបសម្ព័ន្ធទី១)។

២០- អគ្គនាយកដ្ឋានកៅស៊ូ មានមន្ត្រីរាជការសរុបចំនួន១៨២នាក់ ក្នុងនោះស្រីមានចំនួន៥១នាក់ ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋាននិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ ការបែងចែកមន្ត្រីរាជការតាមកម្រិតជំនាញដូចមានខាងក្រោម៖

តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ

| ល.រ | បរិយាយ | កម្រិតសញ្ញាបត្រ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | មធ្យម | | គ្មាន | | សរុប | |
| | | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ |
| ១ | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ | ១ | ១ | ៤ | ៥ | - | - | ១ | - | - | - | **៦** | **៦** |
| ២ | នា.រដ្ឋបាល និងនីតិកម្ម | - | - | ៣ | ៤ | ៨ | ៨ | ៤ | ៣ | ១៧ | ១៥ | **៣២** | **៣០** |
| ៣ | នា.អភិវឌ្ឍន៍កៅស៊ូ | ១ | ១ | ១ | ១ | ២២ | ២២ | ២ | ២ | ៤ | ៤ | **៣០** | **៣០** |
| ៤ | នា.ផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | - | - | ៤ | ៤ | ១៤ | ១៤ | ៣ | ២ | ៦ | ៦ | **២៧** | **២៦** |
| ៥ | នា.កែច្នៃផលិតផលកៅស៊ូ | - | - | ១ | ១ | ១២ | ១៣ | ៤ | ៣ | ៤ | ៤ | **២១** | **២១** |
| ៦ | នា.ទីផ្សារ និងសហ.អន្តរជាតិ | - | - | ២ | ១ | ១៣ | ១៣ | ៤ | ៤ | ៧ | ៥ | **២៦** | **២៣** |
| ៧ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ១ | ១ | ៨ | - | ២៨ | ៣៩ | ៦ | ៦ | ៧ | - | **៥០** | **៤៦** |
| សរុប | | **៣** | **៣** | **២៣** | **១៦** | **៩៧** | **១០៩** | **២៤** | **២០** | **៤៥** | **៣៤** | **១៩២** | **១៨២** |

## ២.១.២ ការងារនីតិកម្ម

២១- ក្នុងឆ្នាំ២០១៨ អគ្គនាយកដ្ឋានកៅស៊ូបាន៖

- ធ្វើបច្ចុប្បន្នភាពសារាចរណែនាំលេខ១០សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការទប់ស្កាត់ការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស ទៅជាសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសវិញ
- បន្តពិនិត្យ កែសម្រួល សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់សេចក្តី-ព្រាងច្បាប់ស្តីពីកៅស៊ូជាមួយគ្រប់ភាគីពាក់ព័ន្ធ។ សេចក្តីព្រាងច្បាប់នេះមានគោលបំណងធានាការគ្រប់គ្រង ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ធានានិរន្តរភាពផលិតកម្មកៅស៊ូ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងរួមចំណែករក្សានិរន្តរភាពបរិស្ថានធម្មជាតិ។ ការពារផលប្រយោជន៍កសិករ ពាណិជ្ជករ និងស្ថាប័នរដ្ឋ
- ចេញសេចក្តីជូនដំណឹងស្តីពីការបង្កើតរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូ
- ចូលរួមដោះស្រាយទំនាស់ដីចម្ការកៅស៊ូដែលពាក់ព័ន្ធជាមួយបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ និង
- ចូលរួមដោះស្រាយការចេញលិខិតអនុញ្ញាតបើកស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ជាមួយអង្គភាពពាក់ព័ន្ធ។

## ២.១.៣ ការងារផ្សព្វផ្សាយ បណ្តុះបណ្តាល និងសិក្ខាសាលា

២២- ការងារដែលអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តក្នុងឆ្នាំ២០១៨រួមមាន៖

១. បានចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូងនិងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន៧វគ្គ នៅខេត្តគោលដៅចំនួន០៧ខេត្តគឺ ខេត្តស្វាយរៀង រតនគិរី ស្ទឹងត្រែង ក្រចេះ កំពង់ធំ ព្រះវិហារ និងប៉ៃលិន ដោយមានកសិករចូលរួមសរុប៣៣៨នាក់(ស្រី៦៦នាក់)។

២. បានចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន១០វគ្គ នៅខេត្តគោលដៅចំនួន១០ គឺខេត្តបាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ កំពង់ចាម ត្បូងឃ្មុំ មណ្ឌលគិរី និងក្រចេះ ដោយមានកសិករចូលរួមសរុប៥១០នាក់(ស្រី៩១នាក់)។

៣. បានចុះបើកវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពី "វិធានការបង្កើនថ្លៃកៅស៊ូធម្មជាតិក្នុងស្រុក" ដល់កសិករកៅស៊ូគ្រួសារ បានចំនួន០៧វគ្គ នៅខេត្តគោលដៅចំនួន០៧ គឺខេត្តក្រចេះ រតនៈគិរី មណ្ឌលគិរី ព្រះវិហារ កំពង់ធំ សៀមរាប និងឧត្តរមានជ័យ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣៦៩នាក់។

៤. បានចុះបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន១០លើក នៅខេត្តគោលដៅចំនួន១០ គឺខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្វាយរៀង កំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរ-មានជ័យ ប៉ៃលិន និងកោះកុង ដែលមានប្រតិបត្តិករកៅស៊ូចូលរួមសរុបចំនួន៥២១នាក់។

៥. បានចុះបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ នៅស្រុកគោលដៅចំនួន០៩ក្នុង០៩ខេត្តគឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ រតនគិរី ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ បាត់ដំបង និងសៀមរាប ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៤៥០នាក់។

៦. បានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញលើប្រធានបទ "ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងអង្គភាព" ដល់មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ ចំនួន០១វគ្គ រយៈពេល០៣ថ្ងៃ ដោយមានមន្ត្រីចូលរួមសរុប៤៥នាក់។

៧. បានបណ្តុះបណ្តាលធនធានមនុស្សនិងផ្ទេរនូវបច្ចេកវិទ្យាតាមរយៈ ការសម្របសម្រួលទស្សនកិច្ចសិក្សាចំនួន៧៦នាក់ (ខ្មែរចំនួន៤២នាក់និងបរទេសចំនួន៣៤នាក់) និងបានដឹកនាំសរសេរសារណាបញ្ចប់ការសិក្សារបស់និស្សិតចំនួន០៨នាក់ និងបានបញ្ជូនមន្ត្រីចំនួន៦នាក់ ទៅបង្រៀននិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

៨. បានចុះបើកវគ្គសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោលចំនួន១វគ្គ ដែលមានរយៈពេល០៣ថ្ងៃ នៅខេត្តរតនគិរី ដែលមានមន្ត្រីមកពីការិយាល័យកៅស៊ូតាមបណ្តាខេត្តចំនួន១៩ខេត្ត (ខេត្តរតនគិរី ត្បូងឃ្មុំ មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពត កោះកុង និងព្រះសីហនុ) សរុបចំនួន៣៥នាក់(ស្រី៥នាក់)។

៩. បានបើវគ្គបណ្តុះបណ្តាលស្តីពី "ស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោក" ចំនួន២វគ្គ (នៅខេត្តកំពង់ចាមនិងខេត្តពោធិ៍សាត់) ដល់មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ មន្ត្រីការិយាល័យកៅស៊ូតាមខេត្ត និងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម សរុបចំនួន៨០នាក់។

១០. បានបើវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំថវិកាកម្មវិធី" ចំនួន១វគ្គ ដែលប្រព្រឹត្តិទៅនៅអគ្គនាយកដ្ឋានកៅស៊ូ ដោយមានការចូលរួមពីមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូនិងមន្ត្រីការិយាល័យកៅស៊ូតាមខេត្ត សរុបចំនួន៣០នាក់។

១១.- បានចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារបានចំនួន៥សហគមន៍ នៅខេត្តគោលដៅចំនួន៥ គឺខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង ប៉ៃលិន និងខេត្តស្ទឹងត្រែង

- បានចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារចំនួន៣ថ្មីបន្ថែមទៀត នៅក្នុងខេត្តគោលដៅចំនួន៣គឺខេត្តកំពង់ធំ កំពង់ចាម និងខេត្តមណ្ឌលគិរី។

១២.- ផ្សាយតម្លៃកៅស៊ូប្រចាំសប្តាហ៍តាមប៉ុស្តិ៍វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM103.5) បានចំនួន៤៨ដង (៤ដង/ខែ) ដើម្បីឱ្យកសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូក្តាប់បានតម្លៃកៅស៊ូលើទីផ្សារតាមតំបន់ក្នុងប្រទេស និងក្រៅប្រទេស

- បោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែបានចំនួន២.១៦០ច្បាប់ សម្រាប់ចែកជូនកសិករកៅស៊ូគ្រួសារ និងអ្នកពាក់ព័ន្ធដែលជាចំណេះដឹងបន្ថែមអំពីអនុវិស័យកៅស៊ូ។

១៣. បើកវគ្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ២០១៦-២០២៥" ប្រព្រឹត្តិទៅនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានកៅស៊ូ ដែលមានការចូលរួមពីមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត តំណាងសមាគមអភិវឌ្ឍកៅស៊ូកម្ពុជា សហគមន៍កសិកម្មកៅស៊ូគ្រួសារ ក្រុមហ៊ុនចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ម្ចាស់រោងចក្រសិប្បកម្មកែច្នៃឈើនិងជ័រកៅស៊ូ សរុបចំនួន១២០នាក់។

១៤.បើកវគ្គសិក្ខាសាលាស្តីពី "ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២៣ ខែមិថុនា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានកៅស៊ូ ដែលមានការចូលរួមពីមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) និងមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិនៃការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ (CIRAD) សរុបចំនួន៥០នាក់។

១៥. បើកវគ្គសិក្ខាសាលាពិគ្រោះយោបល់សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៨ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទក្រសួង សមាគមន៍អភិវឌ្ឍន៍កៅស៊ូកម្ពុជា ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម សហគមន៍កសិកម្មកៅស៊ូគ្រួសារ និងអ្នកពាក់ព័ន្ធ សរុបចំនួន១១០នាក់។

២៣- ការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ៖

- បានបញ្ជូនមន្ត្រីជំនាញចំនួន២នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១១ ដល់១៤ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានបញ្ជូនមន្ត្រីជំនាញចំនួន៣នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធី" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ដល់២៦ ខែមិថុនា ឆ្នាំ២០១៨ នៅខេត្តកំពង់ចាម
- បានបញ្ជូនមន្ត្រីជំនាញចំនួន៣នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធីតាមប្រព័ន្ធកុំព្យូទ័រ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ដល់២៦ ខែតុលា ឆ្នាំ២០១៨ នៅខេត្តកំពង់ចាម
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "Agriculture Engineering" រយៈពេល០២ឆ្នាំ នៅប្រទេសថៃ។

២៤- ការចូលរួមវគ្គសិក្ខាសាលាផ្សេងៗ៖

- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "ការលើកកម្ពស់សមាសភាពយេនឌ័រក្នុងវិស័យកសិកម្មអភិវឌ្ឍន៍ជនបទ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានបញ្ជូនមន្ត្រីជំនាញចំនួន២នាក់ទៅចូលរួមសិក្ខាសាលាស្តីពី "កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៩-២០២១" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១៨ នៅខេត្តកំពត

- បានបញ្ជូនមន្ត្រីជំនាញចំនួន៥នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "របាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាឆ្នាំ២០១៧ និងទិសដៅសម្រាប់អនុវត្តថវិកាកម្មវិធីឆ្នាំ២០១៨ របស់រដ្ឋបាលកណ្តាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២១-២៤ ខែមីនា ឆ្នាំ២០១៨ នៅខេត្តកែប
- បានបញ្ជូនមន្ត្រីជំនាញចំនួន២នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "ការអនុវត្តកាតព្វកិច្ចនៃសមាជិករបស់កម្ពុជាក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងៗពាក់ព័ន្ធនិងវិស័យកសិកម្ម" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០៦-១២ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តកំពត
- បានបញ្ជូនមន្ត្រីជំនាញចំនួន៣នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "Climate Finance And Project Development" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៧-៣១ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តបាត់ដំបង
- បានបញ្ជូនមន្ត្រីជំនាញចំនួន២នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "គោលការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានបញ្ជូនមន្ត្រីជំនាញចំនួន៥នាក់ទៅចូលរួមសិក្ខាសាលាស្តីពី "ការបញ្ជ្រៀបដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធបច្ចេកទេសព័ត៌មានសម្រាប់ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២០-២៣ ខែមិថុនា ឆ្នាំ២០១៨ នៅខេត្តសៀមរាប
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "កម្មវិធីសិក្សារបស់សាលាជាតិកសិកម្មកំពង់ចាម" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០៨-១០ ខែសីហា ឆ្នាំ២០១៨ នៅខេត្តកំពង់ចាម
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "កម្មវិធីសិក្សារបស់សាលាជាតិកសិកម្មព្រែកលៀប" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ
- បានបញ្ជូនមន្ត្រីជំនាញចំនួន៤នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២១ ខែកញ្ញា ឆ្នាំ២០១៨ នៅខេត្តសៀមរាប
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "ការបញ្ជ្រាបយេនឌ័រនិងកុមារក្នុងវិស័យកសិកម្ម" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២១-២៤ ខែតុលា ឆ្នាំ២០១៨ នៅខេត្តកំពត
- បានបញ្ជូនមន្ត្រីជំនាញចំនួន៤នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី "ការអនុវត្តចំណូល ចំណាយថវិកា១០ខែ ឆ្នាំ២០១៨ និងបញ្ហាប្រឈមក្នុងពេលអនុវត្តថវិការបស់រដ្ឋបាលកណ្តាល និងមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមសិក្ខាសាលាបូកសរុបការងារយេនឌ័រប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៤ ដល់១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខេត្តសៀមរាប
- បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមសិក្ខាសាលាស្តីពី "កម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សាបច្ចេក-ទេសកសិកម្មទាំងបី" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៨ នៅខេត្តកំពត។

## ២.២ ការងារផែនការនិងហិរញ្ញវត្ថុ

### ២.២.១ ការងារផែនការ

២៥- ដើម្បីសម្រេចគោលបំណងនិងគោលដៅវិស័យកសិកម្មដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ពិសេសផ្នែកកៅស៊ូ អគ្គ-នាយកដ្ឋានកៅស៊ូដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តអនុកម្មវិធីចំនួន៣ ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន១២៖

១. អនុកម្មវិធីទី១.៥៖ ជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព

- ១.៥.១ ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនិងមន្ត្រីបង្គោល
- ១.៥.២ ពង្រឹងនិងចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ១.៥.៣ ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ
- ១.៥.៤ បណ្តុះបណ្តាលនិងផ្សព្វផ្សាយទីផ្សារកៅស៊ូ។

២. អនុកម្មវិធីទី១.៦៖ ពង្រឹងការរៀបចំ ការអនុវត្តផែនការ និងអភិបាលកិច្ច

- ១.៦.១ តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព
- ១.៦.២ តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ
- ១.៦.៣ គ្រប់គ្រងនិងគាំទ្រកិច្ចការរដ្ឋបាល
- ១.៦.៤ ប្រជុំរៀបចំនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- ១.៦.៥ បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៣. អនុកម្មវិធីទី១.៧៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាពគុណភាពផលិតផលកៅស៊ូកម្ពុជា

- ១.៧.១ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ
- ១.៧.២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ
- ១.៧.៣ ទទួលធ្វើសាវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

២៦- ឆ្នាំ២០១៨ ជាដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្សារភ្ជាប់ថវិកានិងគោលនយោបាយ ជាពិសេសលទ្ធផលដែលអនុវត្តបាន ត្រូវវាស់វែងផ្អែកលើគោលដៅសូចនាករ។ សមិទ្ធផលផ្នែកកៅស៊ូដែលសម្រេចបានតាមបណ្តាចង្កោមសកម្មភាពនៃអនុកម្មវិធីនីមួយៗ របស់ថវិកាកម្មវិធីក្នុងឆ្នាំនេះអាចវាយតម្លៃបានថា មានការរីកចម្រើនគួរជាទីមោទកភាព (ឧបសម្ព័ន្ធទី២)។

២៧- បានរៀបចំកសាងគម្រោងផែនការថវិកាកម្មវិធីឆ្នាំ២០១៩ សម្រាប់អគ្គនាយកដ្ឋានកៅស៊ូទាន់ពេលវេលា និងទទួលបានការអនុម័តយល់ព្រមផ្តល់ថវិកាសម្រាប់គម្រោងថវិកាកម្មវិធីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអនុកម្មវិធីចំនួន៣ និងចង្កោមសកម្មភាពចំនួន១២ ក្នុងនោះវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមាន១អនុកម្មវិធីដែលមានចង្កោមសកម្មភាពចំនួន៣ (ឧបសម្ព័ន្ធទី៣)។

២៨- បានបញ្ចប់កិច្ចប្រជុំពិភាក្សាកម្រិតក្រុមការងារស្តីពីការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា និងត្រៀមដាក់ឆ្លងថ្នាក់ដឹកនាំដើម្បីពិនិត្យ កែសម្រួល។

២៩- បានចុះពិនិត្យទីតាំងស្នើសុំបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូ និងចេញលិខិតអនុញ្ញាតសុំបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ បានចំនួន៨បន្ថែមទៀត នៅក្នុងខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តរតនគិរី។

## ២.២.២ ការងារហិរញ្ញវត្ថុ

៣០- ការងារដែលបានអនុវត្តក្នុងឆ្នាំ២០១៨រួមមាន៖

- រៀបចំគម្រោងចំណាយថវិកាកម្មវិធី និងស្នើសុំគោលការណ៍ចំណាយថវិការជូនទេយ្យបុរេប្រទានសម្រាប់អនុវត្តក្នុងឆ្នាំ
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងស្នើសុំគោលការណ៍ធានាចំណាយថវិកាលើការងារលទ្ធកម្មទូទៅ ប្រេងឥន្ធនៈ សម្ភារការិយាល័យ សង្ហារឹម ឧបករណ៍បច្ចេកទេស សំលៀកបំពាក់ស្ទ័យការពារ ជួសជុលរថយន្ត និងជួសជុលអាគារ ធ្វើការដេញថ្លៃ និងធ្វើការប្រគល់ ទទួលបានរួចក្នុងឆ្នាំ
- រៀបចំសក្ខីប័ត្របញ្ចប់លើការងារទូទាត់ថវិកាកម្មវិធីទាំង៤ជំហ៊ាន និង
- រៀបចំការចុះបញ្ជីសារពើភ័ណ្ឌកើន-ថយ ទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

៣១- ធ្វើការជាប្រចាំជាមួយនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំឯកសារនានាពាក់ព័ន្ធ ចំណាយថវិកានិងអនុវត្តគម្រោងផែនការ និងការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

៣២- ថវិកាអនុម័តឆ្នាំ២០១៨ មានចំនួន៤.៤៣៧,២លានរៀល ធៀបនឹង២០១៧ មានចំនួន២.៨៩៧,៧លានរៀល គឺមានការកើនឡើង១.៥៣៩,៥លានរៀល ស្មើនឹង១៥៣,១%។ ក្នុងនោះជំពូក៦០ ការទិញ មានការកើនចំនួន១០០លានរៀល ជំពូក៦១ សេវាខាងក្រៅ មានការកើនចំនួន១៨០លានរៀល ជំពូក៦៣ ពន្ធនិងអាករ មានការកើនចំនួន១លានរៀល ជំពូក៦៤ ជាការចំណាយទៅលើបន្ទុកបុគ្គលិក មានការកើនឡើងចំនួន ១.២៥៦,៥លានរៀល និងជំពូក៦៥ ការឧបត្ថម្ភធន និងជំនួយសង្គម កើនឡើងចំនួន២លាន(ដ្យាក្រាមទី១)។




ដ្យាក្រាមទី១ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០១៧និង២០១៨

៣៣- ការអនុវត្តថវិកាប្រចាំឆ្នាំសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូ (លើកលែងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) ក្នុងរយៈពេល៩ឆ្នាំនេះ គឺមានការកើនឡើងគួរឱ្យកត់សម្គាល់ពី១ ៤៣២,៧លានរៀល នៅឆ្នាំ២០១០ ដល់៤៣៤០,៤លានរៀល នៅឆ្នាំ២០១៨ ជាមួយនឹងអត្រាកំណើនសមាសប្រចាំឆ្នាំ(CAGR: Compound annual growth rate)១៣,១% ក្នុង១ឆ្នាំ។ បើធៀបនឹងថវិកាអនុម័ត ការអនុវត្តថវិកាក្នុងរយៈពេល៩ឆ្នាំសម្រេចបានពី៩៦,៩៣% ទៅ១២៤,៩៥%។ ការចំណាយខ្ពស់ដល់ទៅ១២៤,៩៥% នៅឆ្នាំ២០១៧ បណ្តាលមកពីមានការចំណាយ

លើសនៃបន្ទុកបុគ្គលិក ប៉ុន្តែជារួមកម្រិតអនុវត្តផែនការថវិកាទាំងនេះ អាចចាត់ទុកថាបានអនុវត្តក្នុងកម្រិតល្អ (ដ្យាក្រាមទី២)។




ដ្យាក្រាមទី២ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៨

៣៤- ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូ បានមកពីការជួលដីរបស់ក្រុមហ៊ុនអវិនិយោគទាំង០៧ ការជួលដីសហគ្រាសសាធារណៈថ្នាក់រដ្ឋបាលកណ្តាល (ចម្ការកៅស៊ូឡាបានសៀក) និងការជួលអចលនវត្ថុ (អសង្ហារឹម) ក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូ។ ក្នុងឆ្នាំ២០១៨ អនុវត្តបានចំនួន១.៥៥៤.៣៦៦.០៤៦រៀល (៣៨៨.៥៩១,៥១ដុល្លារអាម៉េរិក) បើធៀបនឹងគោលដៅចំនួន១.៤០៤.៨០០.០០០រៀល (៣៥១.២០០ដុល្លារអាម៉េរិក) មានកើនលើសចំនួន១៤៩.៥៦៦.០៤៦រៀល (៣៧.៣៩១,៥១ដុល្លារអាម៉េរិក) ស្មើនឹង១០,៦៥% (ឧបសម្ព័ន្ធទី១៦)។

៣៥- សហការជាមួយគណៈប្រតិភូអធិការកិច្ចសវនកម្មផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈប្រតិភូអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច គណៈប្រតិភូអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ (ការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ) ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋក្នុងការិយបរិច្ឆេទឆ្នាំ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធ។

## ២.៣ ការងារអភិវឌ្ឍន៍

### ២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ

៣៦- នៅឆ្នាំ២០១៨នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបចំនួន៤៣៦.៦៨២ហិកតា បើធៀបទៅនឹងឆ្នាំ២០១៧ មានចំនួន៤៣៦.៣៤០ហិកតា កើនឡើងចំនួន៣៤២ហិកតា ស្មើនឹង០,០៨%។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺៈ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម(អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៧៥.៥៧៩ហិកតា ស្មើនឹង៦៣,១០% និងកៅស៊ូគ្រួសារមានចំនួន១៦១.១០៣ហិកតា ស្មើនឹង៣៦,៩០% នៃផ្ទៃដីកៅស៊ូសរុប (តារាងទី២ ដ្យាក្រាមទី៣និងដ្យាក្រាមទី៤)។

តារាងទី២ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៨ (ហិកតា)

| ប្រភេទចម្ការកៅស៊ូ | ចៀរជ័រ | ថែទាំ | សរុប | ភាគរយ |
|---|---|---|---|---|
| **១.ចម្ការកៅស៊ូកសិឧស្សាហកម្ម** | *៨២.១១២* | *១៩៣.៤៦៧* | *២៧៥.៥៧៩* | *៦៣,១០* |
| -អតីតចម្ការកៅស៊ូរដ្ឋនិងវ.ស.ក.ក. | ៣៧.១៩០ | ១៣.៨២២ | ៥១.០១២ | ១១,៦៨ |
| -ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | ៤៤.៩២២ | ១៧៩.៦៤៥ | ២២៤.៥៦៧ | ៥១,៤២ |
| **២. ចម្ការកៅស៊ូគ្រួសារ** | *១១៩.៨៣៧* | *៤១.២៦៦* | *១៦១.១០៣* | *៣៦,៩០* |
| សរុប | **២០១.៩៤៩** | **២៣៤.៧៣៣** | **៤៣៦.៦៨២** | **១០០** |

សម្គាល់៖ វ.ស.ក.ក.៖ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា




ដ្យាក្រាមទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៨ (%)




ដ្យាក្រាមទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៤-២០១៨ (ហិកតា)

៣៧- ឆ្នាំ២០១៨នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន២០១.៩៤៨ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៧ មាន ១៧០.២៣០ហិកតា កើនឡើងចំនួន៣១.៧១៨ហិកតា ស្មើនឹង១៨,៦៣% (ដ្យាក្រាមទី៥)។ ផលិតផលកៅស៊ូសម្រេចបានចំនួន២២០.១០០តោន ធៀបនឹងឆ្នាំ២០១៧ ចំនួន១៩៣.២៨៦តោន កើនឡើងចំនួន ២៦.៨១៤តោន ស្មើនឹង១៣,៨៧%។ ទិន្នផលមធ្យមចំនួន ១.០៩០គ.ក្រ./ហ.ត. ធៀបនឹងឆ្នាំ២០១៧ មានចំនួន១.១៣៥គ.ក្រ./ហ.ត. គឺថយចុះ៣,៩៦% (ឧបសម្ព័ន្ធទី៤)។ ចំណែកស្ថិតិផ្ទៃដីកៅស៊ូលម្អិតមានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី៤ ទី៦ ទី៧ ទី៨ ទី៩ ទី១០ ទី១១ ទី១២ ទី១៣ និងទី១៤។




ដ្យាក្រាមទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុបឆ្នាំ២០១៤-២០១៨ (ហិកតា)

៣៨- ការនាំចេញកៅស៊ូធម្មជាតិក្នុងឆ្នាំ២០១៨ សម្រេចបានចំនួន២១៧.៥០០តោន ស្មើនឹងទឹកប្រាក់ចំនួន ២៨៦.៩៤៤.៥២៨ដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០១៧ ដែលការនាំចេញ មានចំនួន១៨៨.៨៣២តោន ស្មើនឹងទឹកប្រាក់ចំនួន២៩៨.៦១៩.៧២១ដុល្លារអាម៉េរិក គឺផលិតផលកៅស៊ូធម្មជាតិនាំចេញកើនឡើងចំនួន ២៨.៦៦៨តោន ស្មើនឹង១៥,១៨%(ដ្យាក្រាមទី៦, ឧបសម្ព័ន្ធទី៥)។ ទឹកប្រាក់ចំណូលថយចុះប្រមាណ ១១.៦៧៥.១៩៣ដុល្លារអាម៉េរិក ស្មើនឹង៣,៩០%។ ចំពោះតម្លៃកៅស៊ូជាមធ្យម១.៣១៩ដុល្លារអាម៉េរិកក្នុងមួយតោន ធៀបនឹងឆ្នាំ២០១៧ មានតម្លៃមធ្យម១.៥៨១ដុល្លារអាម៉េរិកក្នុងមួយតោន គឺថយចុះចំនួន២៦២ ដុល្លារអាម៉េរិកក្នុងមួយតោន ស្មើនឹង១៦,៥៧%។ អាស្រ័យដោយ (១)តម្លៃកៅស៊ូធម្មជាតិ នៅលើទីផ្សារទិញ-លក់ភ្លាមៗនៅតែទាប (២)សំណល់សន្និធិកៅស៊ូច្រើននៅក្នុងឃ្លាំងនានា នៃទីផ្សារក្រុងសៀងហៃ និងនៅមជ្ឈមណ្ឌលពាណិជ្ជកម្មសេរីក្រុងក្វាងទុង (៣)ក្ដីកង្វល់និងការបារម្ភនានាអំពីការធ្លាក់ចុះសេដ្ឋកិច្ចចិន ដោយសារតែសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិច និងប្រទេសចិន រួមនឹងគោលនយោបាយសងសឹកគ្នា ទៅវិញទៅមកលើការយកពន្ធគយរៀងៗខ្លួនរបស់មហាយក្សសេដ្ឋកិច្ចទាំងពីរ និង(៤)ឥទ្ធិពលនៃកត្តាខាងក្រៅផ្សេងៗទៀត នៅតែរក្សាស្ថានភាពរំញោចទីផ្សារកៅស៊ូធម្មជាតិពិភពលោកធ្លាក់ចុះដដែល។




ដ្យាក្រាមទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១៣-២០១៨

## ២.៣.២ ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ

៣៩- គិតចាប់ពីឆ្នាំ២០១៣ រហូតមកដល់ឆ្នាំ២០១៨នេះ រោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូនិងឈើកៅស៊ូមានចំនួនសរុប១៤៧កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមបច្ចេកទេស(TSR: Technically Specified Rubber) ចំនួន៤១កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់(CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន៩៤កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន១១កន្លែង (ដ្យាក្រាមទី៧, ឧបសម្ព័ន្ធទី១៥)។




ដ្យាក្រាមទី៧ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ និងឈើកៅស៊ូ២០១៣-២០១៨

៤០- អត្រាគុណភាពផលិតផលកៅស៊ូ (CSR L, CSR 5, CSR 10) ក្នុងឆ្នាំ២០១៣ មានចំនួន៧១ភាគរយ ក្នុងឆ្នាំ២០១៤ មានចំនួន៧៣ភាគរយ ឆ្នាំ២០១៥ មានចំនួន៧៥ភាគរយ ឆ្នាំ២០១៦ មានចំនួន៧៦,៦៣ភាគរយ ឆ្នាំ២០១៧ មានចំនួន៧៧ ភាគរយ និងក្នុងឆ្នាំ២០១៨ មានចំនួន៧៨ភាគរយ(ដ្យាក្រាមទី៨)។




ដ្យាក្រាមទី៨ អត្រាគុណភាពផលិតផលកៅស៊ូ (CSR L, CSR 5, CSR 10) ២០១៣-២០១៨

៤១- សំណើសុំគោលការណ៍អនុញ្ញាតបង្កើតរោងចក្រកែច្នៃឈើកៅស៊ូចំនួន២កន្លែង ដោយបានទទួលប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ២.៤ ការងារពិសោធន៍និងស្រាវជ្រាវ

៤២- ការងារស្រាវជ្រាវ និងពិសោធន៍បានចូលរួមជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកដំណាំកៅស៊ូទាំងផ្នែកបច្ចេកទេស សុវុឌ្ឍិកម្មកូនកៅស៊ូ គុណភាពជ័រកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (**វសកក**) បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូសំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជា ដែលមានសក្តានុពលបន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខណ្ឌបរិស្ថាន នៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ **វសកក** បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្សដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្សតាមរយៈការបង្ហាត់បង្រៀននិស្សិតនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍ និងការដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។

៤៣- ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ៖

- ការស្រង់ ការបញ្ចូល និងវិភាគទិន្នន័យគ្រប់ចម្ការពិសោធមានចំនួន៦០ក្នុងបរិវេណស្ថានីយ៍អនុវត្ត និងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ
- ការរៀបចំរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១៧-២០១៨
- ថែទាំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៧-២០១៨លើផ្ទៃដី០,៣៥ហិកតា
- អនុវត្តការងារបំបៅកូនកៅស៊ូចំនួន៤២ក្លូន
- ការរៀបចំថ្នាលបណ្តុះកូនកៅស៊ូថ្មីសម្រាប់ឆ្នាំ២០១៨-២០១៩ ចំនួន០,៣៥ហិកតា

- កាប់ចង្ហួរនិងច្រកដីចូលថង់សម្រាប់ថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០១៨-២០១៩ ចំនួន៣៥ ០០០ថង់
- ដាក់គ្រាប់បណ្ដុះក្នុងថង់សម្រាប់ថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០១៨-២០១៩ ចំនួន៣៥ ០០០ថង់
- អនុវត្តការសាកល្បងបំបៅមីនីកូនកៅស៊ូតូច (Mini-Budding) ចំនួន៣០០០កូនដោយសហការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិនពីថ្ងៃទី១០-១៩ ខែកញ្ញា ឆ្នាំ២០១៨
- ការរៀបចំកូនកៅស៊ូក្នុងបំពង់ Root Trainer ចំនួន៣ក្លូន GT 1(២២០ដើម) IRCA 230 (៧២០ដើម) និង RRIM 600 (២០០ដើម)
- ការថែទាំចម្ការសមុច្ច័យដំណាំគ្របដីចំនួន១៧ប្រភេទ
- ការថែទាំកូនកៅស៊ូចម្ការពិសោធចំនួន៧១,៥ហិកតា
- ការរៀបចំដី និងដាំដុះកូនកៅស៊ូឆ្នាំ២០១៨ ចំនួន១៩ហិកតា
- ការដាំជួសកូនកៅស៊ូដាំឆ្នាំ២០១៧នៅប្លុក៥២CN លើផ្ទៃដីចំនួន១២,៥ហិកតា
- ការដាំជួសកូនកៅស៊ូដាំឆ្នាំ២០១៨នៅប្លុក៥២CS លើក្លូន IRCA 230 (១២,៥ហ.ត) និងប្លុក៤២BNW លើក្លូន GT 1 (៦,៥ហ.ត)
- ដាំដំណាំចន្លោះរងកៅស៊ូនៅប្លុក៥២CSចំនួន៥ប្រភេទមាន ចេក ខ្នុរ ស្វាយ ម្នាស់ និងស្វាយចន្ទី
- ដាំដំណាំគ្របដីចំនួន៣ប្រភេទនៅប្លុក៤២BNW មាន (Stylosanthes Guiannensis, Mucuna Aterrinum, Pueraria Phaseoloides)
- ការដាក់ជីបំប៉នកូនកៅស៊ូចំនួនពីរលើកលើផ្ទៃដី៦៨ហិកតា
- ការស្រង់ទិន្នន័យជំងឺម្សៅប្រផេះស (Oidium) នៅតាមបណ្ដាចម្ការពិសោធក្លូនចំនួន២៦ពិសោធន៍
- ការស្រង់ទិន្នន័យដើមកៅស៊ូកើតជំងឺស្ងួតផ្ទាំងចៀរ (TPD) នៅតាមបណ្ដាចម្ការពិសោធសរីរសាស្ត្រនិងអាជីវកម្មចំនួន១៤ពិសោធន៍
- ការបាញ់ថ្នាំព្យាបាលជំងឺកុលាប (Pink Disease) នៅតាមប្រគៀបមែកកៅស៊ូចាប់ពីកៅស៊ូអាយុ០៣-១០ឆ្នាំចំនួន០៣ជុំ លើផ្ទៃដីចំនួន១៦២ហិកតា
- ការបង្កើតច្បារពូជថ្មីក្រោមគម្រោងធម្មនិយាមកម្មចំនួន២,៥ហិកតា
- ចុះយកសំណាកស្លឹកកៅស៊ូនៅចម្ការកៅស៊ូពាក់ព័ន្ធនឹងការសិក្សា អំពីជីជាតិដីនៅតាមបណ្ដាខេត្តដែលបានដាំដុះកៅស៊ូដើម្បីវិភាគរកសារធាតុចិញ្ចឹមសរុបមានចំនួន១៣០ទីតាំងស្មើនឹង១៣០សំណាក
- ចុះរៀបចំបើកមុខចៀរជ័រចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ ដែលបានសហការជាមួយក្រុមហ៊ុនសុកហ៊ីនកា សេ ដេ ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរីបានចំនួន១ចម្ការពិសោធន៍
- ការវិភាគ DRC និង TSC ចំនួន០៣ដង គ្រប់ចម្ការពិសោធក្នុងស្ថានីយ៍ ដោយមេត្រូឡាក់ និងការដុតក្នុងបន្ទប់ពិសោធ
- ផ្ទៀងផ្ទាត់គុណភាពវត្ថុធាតុគីមី សម្រាប់វិភាគសរីរសាស្ត្រទឹកជ័រចំនួន១៧លើក
- ការវិភាគ LD គ្រប់ចម្ការពិសោធក្នុងស្ថានីយ៍បានចំនួន៧៣៦សំណាក។

៤៤- ការងារក្នុងផ្នែកមន្ទីរពិសោធយថាប្រភេទ៖

- ការធ្វើតេស្តយថាប្រភេទកៅស៊ូបានចំនួន៣៤៥ភាគសំណាក សម្រាប់ធ្វើការវាយតម្លៃសមត្ថភាព និងគុណភាពជ័រដែលបានកែច្នៃដោយបណ្ដារោងចក្រ
- ការប្រៀបធៀបលទ្ធផលនៃការធ្វើតេស្ត មន្ទីរពិសោធក្នុងស្រុក (Laboratories Parallel Test) លើកទី៥២ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធមូលដ្ឋាន យោងតាមប្រកាសលេខ៤០៤ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចូលរួមធ្វើតេស្ត Round Robin ចំនួន២លើកជាមួយប្រទេសម៉ាឡេស៊ី
- បានចុះបញ្ជិកាពោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋានឱ្យក្រុមហ៊ុនសុភក្តិនីកាអិនវេសមេនគ្រុប ខូ., អិលធីឌី ដែលមានអសយដ្ឋាន ភូមិ០៦ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- បានចុះបញ្ជិកាពោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋានឱ្យក្រុមហ៊ុនសុភក្តិនីកាអិនវេសមេនគ្រុប ខូ., អិលធីឌី ដែលមានអសយដ្ឋាន ភូមិខោល ឃុំទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ
- បន្តបញ្ជិកាពោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋានឱ្យក្រុមហ៊ុនស៊ីហ្វ វីសសស៍ លីមីធីត ដែលមានអសយដ្ឋាន ភូមិ០៦ ឃុំរោងចក្រ ស្រុកស្នួល ខេត្តក្រចេះ។

៤៥- ការបោះពុម្ពផ្សាយ៖

ឯកសារជាច្រើនប្រភេទត្រូវបានធ្វើការបោះពុម្ពផ្សាយសំដៅ ផ្ទេរបច្ចេកវិទ្យានិងចែករំលែកព័ត៌មានដល់អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ និយាយជារួមគឺប្រតិបត្តិករកៅស៊ូបានយល់ដឹងអំពីសកម្មភាពផ្សេងៗ ដែល **វសកក** បាននិងកំពុងអនុវត្ត។ ឯកសារដែលបានបោះពុម្ពផ្សាយ រួមមាន៖

- របាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១៦-២០១៧មានចំនួន១៥០ក្បាល
- ឯកសារស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០២០មានចំនួន២០០០ច្បាប់
- ឯកសារជា Poster មានចំនួន១២ផ្ទាំង។

## ២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

### ២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)

៤៦- សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ(Association of Natural Rubber Producing Countries: ANRPC) គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិកភាពរបស់សមាគមត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ គិតរហូតមកដល់ឆ្នាំ២០១៨ សមាគមនេះមានប្រទេសជាសមាជិកចំនួន១៣ប្រទេស រួមមាន៖បង់ក្លាដេស កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ប៉ាពូញូហ្គីណេ ភីលីពីន សិង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។ <u>**ទស្សនៈវិស័យ**</u> របស់សមាគម គឺធ្វើឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិ មានចីរភាពប្រកបដោយលក្ខណៈសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ <u>**បេសកកម្មរួម**</u> គឺកែលម្អជាបន្តបន្ទាប់នូវផលិតភាពនៃកៅស៊ូគ្រួសារ កាត់បន្ថយចំណាយបង្កើនតម្លៃបន្ថែម ផ្នែកលំហូរខាងក្រោម រកប្រភពប្រាក់ចំណូលបន្ថែម ប្រើប្រាស់លទ្ធភាព និងបទពិសោធន៍កៅស៊ូធម្មជាតិ សម្រាប់ជួយបរិស្ថាននិងបង្កើនសុខុមាលភាពរបស់កសិករកៅស៊ូគ្រួសារ។

៤៧- សកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូនៅក្នុងសមាគម ឆ្នាំ២០១៨កន្លងមកគឺ៖ (១)ចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី"ការស្រាវជ្រាវនិងការវិភាគទីផ្សារកៅស៊ូធម្មជាតិ (ANRPC)" នៅទីក្រុងគូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី០៥-០៨ ខែកុម្ភៈ ឆ្នាំ២០១៨ (២)ចូលរួមកិច្ចប្រជុំលើកទី៥ នៃក្រុមជំនាញផ្នែកស្ថិរភាពតម្លៃកៅស៊ូធម្មជាតិ នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃទី១៧-១៩ ខែមេសា ឆ្នាំ២០១៨ (៣)ចូលរួមសិក្ខាសាលាស្តីអំពី "ឆ្ពោះទៅរកប្រសិទ្ធិភាពខ្សែច្រវ៉ាក់នៃការផ្គត់ផ្គង់" នៅទីក្រុងហាត់យ៉ៃ ប្រទេសថៃ កាលពីថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០១៨ (៤)ចូលរួមសិក្ខាសាលាស្តីអំពី "ការផ្គត់ផ្គង់ តម្រូវការ និងការធ្វើម៉ូឌែលឧស្សាហកម្មកៅស៊ូធម្មជាតិ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)" នៅប្រទេសហ្វីលីពីន កាលពីថ្ងៃទី០២-០៥ ខែកក្កដា ឆ្នាំ២០១៨ និង(៥)ចូលរួមសន្និសីទ សន្និបាត និងកិច្ចប្រជុំប្រចាំឆ្នាំ២០១៨ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅខេត្តឈៀងរ៉ៃ ប្រទេសថៃ ចាប់ពីថ្ងៃទី០៨-១៣ ខែតុលា ឆ្នាំ២០១៨។

តារាងទី៣ កម្មវិធីសន្និសីទកិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៨ របស់ANRPC

| ល.រ | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលអន្តរជាតិលើកទី២ ស្តីពីការ ស្រាវជ្រាវនិងវិភាគទីផ្សារកៅស៊ូ<br>Second International Training in Rubber Market Analysis and Research (R-MART 2018) | ខែកុម្ភៈ ឆ្នាំ២០១៨ | ប្រទេសម៉ាឡេស៊ី |
| ២ | សិក្ខាសាលាស្តីពីសេដ្ឋកិច្ចនៃផ្លូវក្រាលកៅស៊ូនិងសក្តានុពលរបស់វា ធ្វើឱ្យមានតម្រូវការកៅស៊ូបន្ថែមទៀត<br>Seminar on Economics of Rubberized Roads and their Potential to Generate Additional Demand for NR | ខែមីនា ឆ្នាំ២០១៨ | ប្រទេសថៃ |
| ៣ | កិច្ចប្រជុំលើកទី៥របស់ក្រុមជំនាញ ស្តីពីតម្លៃកៅស៊ូ<br>Fifth meeting of Expert Group on NR Price | ខែមេសា ឆ្នាំ២០១៨ | ប្រទេសឥណ្ឌូនេស៊ី |
| ៤ | សិក្ខាសាលាស្តីពីការឆ្ពោះទៅរកប្រសិទ្ធភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់<br>Workshop on “Towards Supply-Chain Efficiency” | ខែមិថុនា ឆ្នាំ២០១៨ | ប្រទេសថៃ |
| ៥ | សិក្ខាសាលាស្តីពីការផ្គត់ផ្គង់ តម្រូវការ និងការធ្វើម៉ូឌែលឧស្សាហកម្មកៅស៊ូ<br>Workshop on Supply, Demand and Modeling of Work Rubber Industry | ខែកក្កដា ឆ្នាំ២០១៨ | ប្រទេសហ្វីលីពីន |
| ៦ | សន្និបាតលើកទី៤១ សន្និសីទកៅស៊ូប្រចាំឆ្នាំលើកទី១១ និងកិច្ចប្រជុំប្រចាំឆ្នាំ<br>41st Session of Assembly, 11th Annual Rubber Conference and Annual Meetings | ខែតុលា ឆ្នាំ២០១៨ | ប្រទេសថៃ |
| ៧ | វគ្គបណ្តុះបណ្តាលកម្រិតអន្តរជាតិស្តីពីការប៉ាន់ស្មាននិងការព្យាករណ៍<br>International Training in Estimation and Forecasting | ខែធ្នូ ឆ្នាំ២០១៨ | ប្រទេសម៉ាឡេស៊ី |

៤៨- ក្នុងឆ្នាំ២០១៩នេះ ប្រទេសជាសមាជិកANRPCនឹងចូលរួមកិច្ចប្រជុំ តាមកាលបរិច្ឆេទដូចខាងក្រោម៖

តារាងទី៤ ព្រឹត្តិការណ៍សំខាន់របស់ ANRPC ក្នុងឆ្នាំ២០១៩

| ល.រ | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|
| ១ | International Training in Rubber Market Analysis and Research (R-MART 2019) | ខែកុម្ភៈ ឆ្នាំ២០១៩ | ប្រទេសម៉ាឡេស៊ី |
| ២ | 6th meeting of Expert Group on NR Price Stabilization | ខែមីនា ឆ្នាំ២០១៩ | ប្រទេសបង់ក្លាដែស |
| ៣ | Workshop on “Supply, Demand and Modelling of NR Industry” | ខែមីនា ឆ្នាំ២០១៩ | ប្រទេសមីយ៉ាន់ម៉ា |
| ៤ | Seminar on Economics of Rubberized Roads | ខែឧសភា ឆ្នាំ២០១៩ | ប្រទេសម៉ាឡេស៊ី |
| ៥ | Workshop on “Towards Supply-Chain Efficiency” | ខែឧសភា ឆ្នាំ២០១៩ | ប្រទេសថៃ |
| ៦ | First meeting of Working Group on Sustainable NR | ខែមិថុនា ឆ្នាំ២០១៩ | ប្រទេសកម្ពុជា |
| ៧ | Annual Events | ខែតុលា ឆ្នាំ២០១៩ | ប្រទេសឥណ្ឌូនេស៊ី |

### ២.៥.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

៤៩- បានទៅចូលរួមសិក្ខាសាលា សន្និសីទកៅស៊ូអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ IRRDB នៅប្រទេសកូដឌីវ័រ ចំនួន១លើក ប្រទេសម៉ាឡេស៊ីចំនួន១លើក និងប្រទេសថៃចំនួន១លើក។

៥០- បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមបណ្តុះបណ្តាល សិក្ខាសាលាអន្តរជាតិ សន្និសីទនិងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ នៅប្រទេសកូដឌីវ័រចំនួន១រូប ប្រទេសស្រីលង្កាចំនួន១រូប និងប្រទេសថៃចំនួន១រូប។

### ២.៥.៣ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

៥១- ក្នុងការពង្រឹងនិងបង្កើននូវប្រសិទ្ធិភាពសិក្សានិងស្រាវជ្រាវអំពីបច្ចេកទេស និងវិទ្យាសាស្ត្រដំណាំកៅស៊ូ **វសកក** បានធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្មសម្រាប់ការ អភិវឌ្ឍ (CIRAD) នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦នៅវសកក។ នៅក្នុងឆ្នាំ២០១៨ជំនាញការ CIRAD បានបំពេញបេសកកម្មចំនួន១ដង នៅកម្ពុជា ដើម្បីពិភាក្សានិងរៀបចំការងារស្រាវជ្រាវ។

៥២- បានអញ្ជើញមន្ត្រីរបស់ CIRAD ចំនួន៤នាក់ មកធ្វើបទបង្ហាញក្នុងសិក្ខាសាលាស្តីពី “ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ” ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២៣ ខែមិថុនា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានកៅស៊ូ។

### ២.៥.៤ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

៥៣- ឆ្នាំ២០១៨ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) សហការជាមួយអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តនូវគម្រោងចំនួន០៣រួមមាន៖

១)បញ្ចប់គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បញ្ចប់សកម្មភាពលើការវិភាគក្លូនលើច្បារពូជកៅស៊ូ នៅស្ថានីយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានទីតាំងនៅខេត្តត្បូងឃ្មុំ សរុបមានចំនួន១០៣០សំណាក។ រីឯលទ្ធផលដែលទទួលបានពីCIRAD គឺទទួលបាននូវភាពត្រឹមត្រូវកំរិតខ្ពស់
- បញ្ចប់ការដាំដុះកូនកៅស៊ូលើច្បារពូជយោង លើផ្ទៃដីសរុបចំនួន១,៤ហិកតា ស្មើនឹង១០០ប្លុក ស្មើនឹង ២២ក្លូន និងបង្កើតច្បារពូជសមុច្ច័យ (Collection budwood garden) លើផ្ទៃដីសរុបចំនួន០,៦ហិកតា
- បញ្ចប់លើការថែទាំច្បារពូជកៅស៊ូឯកជនចំនួន១៨ច្បារពូជ ស្មើនឹង២៣,៤៤ហិកតា ស្ថិតនៅក្នុងខេត្តចំនួន ០៨(១០ស្រុក) គឺខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ ប៉ៃលិន រតនគិរី ស្ទឹងត្រែង និងសៀមរាប
- បញ្ចប់ការផ្តល់វិញ្ញាបនបត្រច្បារពូជកៅស៊ូដល់ម្ចាស់ច្បារពូជសរុបទាំង១៨ និងបានលើកស្លាកសញ្ញានៅតាមទីតាំងច្បារពូជទាំង១៨ ដោយសម្រេចបានលទ្ធផល១០០%
- បញ្ចប់ការចុះប្រមូលទិន្នន័យទិន្នផលកៅស៊ូគ្រួសារប្រចាំខែ នៅតាមខេត្តគោលដៅចំនួន១០(ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ បាត់ដំបង និងប៉ៃលិន) ស្មើនឹង១៣០ចម្ការ។ ក្លូនដែលត្រូវជ្រើសរើស រួមមាន GT 1, RRIM 600 និងPB 260។ ចំពោះទិន្នផលចម្ការកៅស៊ូគ្រួសារ គឺទទួលបានលទ្ធផលល្អប្រសើរ
- បញ្ចប់ការចុះប្រមូលសំណាក និងវិភាគលើគុណភាពជ័រកៅស៊ូយថាប្រភេទនៅតាមបណ្តារោងចក្រកសិ-

ឧស្សាហកម្ម និងឯកជន សរុបចំនួន២៣រោងចក្រ ស្មើ៥១៦សំណាក ស្ថិតនៅក្នុងខេត្តចំនួន៨ រួមមាន ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ កំពង់ធំ រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តព្រះសីហនុ

២) ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ “Climate Smart Rubber Production through promoting Good Agriculture Practices (GAP)”

- បើកវគ្គសិក្ខាសាលាស្តីពី “ផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ” ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២៣ ខែមិថុនា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានកៅស៊ូ
- បានរៀបចំចម្ការពិសោធស្តីពី “Effective of cover crop and fertilizer on Rubber Growth and Production” នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- បានបញ្ជូនមន្ត្រីរបស់អគ្គនាយកដ្ឋានកៅស៊ូចំនួន៨នាក់ ទៅធ្វើទស្សនកិច្ចសិក្សាស្តីពីការអនុវត្តកសិកម្មល្អ លើវិស័យកៅស៊ូ នៅប្រទេសម៉ាឡេស៊ី
- បានរៀបចំទិវាស្រែកសិករនៅចម្ការពិសោធន៍នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

៣) ត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ដោយបាន៖

- បញ្ចប់ការសិក្សាលទ្ធភាពដែលអាចធ្វើបានដំណាក់កាលទី២ នៅខេត្តគោលដៅចំនួន០២ គឺខេត្តរតនគិរី និងខេត្តបាត់ដំបង ដែលចុះសិក្សាដោយក្រុមហ៊ុន GLG Consultant
- បញ្ចប់ចុះសិក្សាពីវិស័យកៅស៊ូធម្មជាតិនៅកម្ពុជា ដែលមានសមាសភាគចំនួន៣ជាបន្ថែមទៀត មុនពេលចាប់ផ្តើមអនុវត្តគម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជារួមមាន (១)ការវិភាគខ្សែច្រវាក់តម្លៃនិងការប្រកួតប្រជែង (Value chain and competitiveness analysis) (២)គុណភាពនិងការនាំចេញផលិតផលកៅស៊ូ (Quality and export of rubber products) និង(៣)ការគ្រប់គ្រងវិស័យកៅស៊ូ (Sector organization)។

## ២.៥.៥ អង្គការស្បៀងអាហារនិងកសិកម្ម (FAO)

៥៤- អគ្គនាយកដ្ឋានកៅស៊ូបានជួបប្រជុំពិភាក្សាការងារជាមួយលោក Pierre-Marie Bosc មន្ត្រីជាន់ខ្ពស់ អង្គការស្បៀងអាហារនិងកសិកម្ម (FAO) និងជាអ្នកសម្របសម្រួលកម្មវិធីឃ្លាំមើលការងារកសិកម្មពិភពលោក (World Agricultural Watch: WAW) ដើម្បីរៀបចំគម្រោងថ្នាក់តំបន់ (Regional Project Formulation) សម្រាប់ប្រទេសកម្ពុជា ភូមា និងថៃ ដោយផ្តោតលើគម្រោងប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារ (Rubber Family Farm Monitoring System Project)។

## ២.៥.៦ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

៥៥- អគ្គនាយកដ្ឋានកៅស៊ូបានជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន HAINAN STATE FARMS INVESTMENT HOLDINGS GROUP CO., LTD. កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ និងបានឯកភាពគ្នាលើចំណុចមួយចំនួនដូចខាងក្រោម៖ (១)គម្រោងឱ្យមានការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកៅស៊ូ (២)គម្រោងទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងវិស័យកៅស៊ូនៅខេត្តហាយ-ណាន (៣)ពង្រឹង ពង្រីក និងគាំទ្រលើកិច្ចសហប្រតិបត្តិការដល់មជ្ឈមណ្ឌលដែលទើបបង្កើតថ្មីលើការងារដាំដុះ គ្រប់គ្រង ស្រាវជ្រាវពូជថ្មីៗដែលបន្សាំនឹងការប្រែប្រួលអាកាស (៤)ពន្លឿនការអនុវត្តបន្តនូវកិច្ចព្រមព្រៀងនានានិងអនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាកន្លងមក និង(៥)បានបញ្ជូនមន្ត្រីជំនាញចំនួន១នាក់ទៅចូលរួមវគ្គសិក្ខាសាលាស្តីពី Developing System of Agriculture Production Marketing for Developing Countries។

### ២.៥.៧ កិច្ចសហប្រតិបត្តិការជាមួយ CATAS

៥៦- កិច្ចសហប្រតិបត្តិការជាមួយ CATAS (Chinese Academy of Tropical Agricultural Sciences) ក្នុងទិសដៅបង្កើននូវសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ។ ***វសកក*** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) ដោយបានចុះអនុស្សរណៈនៃការយោគយល់នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡុមបូ ប្រទេសស្រីលង្កា។ បន្ទាប់ពីនោះគណប្រតិភូ CATAS បានធ្វើទស្សនកិច្ចនៅ ***វសកក*** ចំនួន៦លើក។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ***វសកក*** និង CATAS បានចុះអនុស្សរណៈនៃការយោគយល់បំពេញបន្ថែមដើម្បីបន្តសុពលភាពនៃកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវរួមគ្នា។ ក្នុងឆ្នាំ២០១៨ភាគី CATAS ថ្នាក់ដឹកនាំ ***វសកក*** ទៅទស្សនកិច្ចនៅប្រទេសចិនចំនួន១លើក និងបានបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រី ***វសកក*** ចំនួន៥រូបនៅប្រទេសចិន និងបានចាប់ផ្តើមការពិសោធរួមគ្នានៅកម្ពុជា ***វសកក*** ជាលើកដំបូងអំពី Mini Budding និង Root Trainer និងការងារច្បារបង្កាត់ពូជ។ ភាគី CATAS ក៏បានសន្យាជួយជម្រុញឱ្យមន្ទីរពិសោធន៍ផ្នែកក្សេត្រសាស្ត្រ (វិភាគដីនិងស្លឹកកៅស៊ូ) ឱ្យមានដំណើរការ និងអភិវឌ្ឍនៅពេលខាងមុខ។

### ២.៥.៨ ការរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និងវៀតណាម (CLV-DTA)

៥៧- បានប្រជុំពិនិត្យនិងពិភាក្សាធ្វើការកែតម្រូវនិងធ្វើបច្ចុប្បន្នភាពនូវតួលេខនិងខ្លឹមសារមួយចំនួនលើឯកសារស្តីពីផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិ នៅតំបន់ត្រីកោណអភិវឌ្ឍន៍នៃប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម (CLV DTA) កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានកៅស៊ូ សម្រាប់ត្រៀមដាក់ជូនកិច្ចប្រជុំកំពូលលើកទី១០ថ្នាក់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងបី ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២៨-៣១ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

៥៨- បានទំនាក់ទំនងជាបន្តបន្ទាប់ជាមួយភាគីវៀតណាម ដើម្បីបញ្ចប់របាយការណ៍ចុះសិក្សាស្តីពីផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិ តាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំកំពូលលើកទី១០ រវាងប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម សម្រាប់ដាក់ជូនក្នុងកិច្ចប្រជុំកំពូលលើកទី១១ ដែលនឹងរៀបចំនៅសាធារណៈរដ្ឋប្រជាមានិតឡាវ នាឆ្នាំ២០២០ សម្រាប់ពិនិត្យពិចារណា។

## ៣. បញ្ហាប្រឈម

៥៩- ការអនុវត្តក្នុងឆ្នាំ២០១៨ អគ្គនាយកដ្ឋានកៅស៊ូ បានជួបនូវបញ្ហាប្រឈមនិងការលំបាកមួយចំនួនដូចខាងក្រោម៖

- ខ្វះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាមួយចំនួន
- កិច្ចសហការរវាងអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសពុំទាន់មានប្រសិទ្ធភាពល្អនៅឡើយ
- មិនមានភាពស្មោះត្រង់រវាងកសិករកៅស៊ូគ្រួសារ អ្នកប្រមូលទិញ និងក្រុមហ៊ុនកែច្នៃ
- កិច្ចសហការពីម្ចាស់ចម្ការកៅស៊ូ រោងចក្រសិប្បកម្មមួយចំនួននៅមិនទាន់ល្អ ជាមួយអគ្គនាយកដ្ឋានកៅស៊ូ
- កង្វះមធ្យោបាយដឹកជញ្ជូន

- កង្វះធនធានមនុស្ស ទាំងនៅអគ្គនាយកដ្ឋានកៅស៊ូ និងការិយាល័យកៅស៊ូតាមខេត្ត ព្រមទាំងសមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត
- កសិករកៅស៊ូគ្រួសារមិនទាន់យល់ដឹងពីសារៈប្រយោជន៍សហគមន៍កសិកម្មកៅស៊ូគ្រួសារ
- កង្វះធនធានមនុស្សផ្នែកវិទ្យាសាស្ត្រស្រាវជ្រាវ ដែលបណ្តាលមកពីការផ្លាស់ប្តូរទីតាំង និងការផ្ទេរការងារ
- ការនាំចេញកៅស៊ូរបស់ក្រុមហ៊ុនមួយចំនួនមិនបានបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់កៅស៊ូយថាប្រភេទកម្ពុជា (CSR)
- ការយល់ដឹងពីបច្ចេកវិទ្យាកៅស៊ូថ្មីៗ របស់ប្រតិបត្តិករកៅស៊ូនៅមានកម្រិត
- លទ្ធភាពនៃការប្រមូលព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងឧស្សាហកម្មកៅស៊ូធម្មជាតិ ដែលជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំរបាយការណ៍ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅតែជាបញ្ហាប្រឈមនៅឡើយ
- តម្លៃកៅស៊ូធម្មជាតិមានការប្រែប្រួលខ្លាំងនិងមាននិន្នាការកើនឡើងតិចតួច
- កង្វះទីតាំង និងផ្ទៃដីសម្រាប់សាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងចម្ការបង្ហាញដំណាំកៅស៊ូ នៅតាមតំបន់ដែលមានសក្តានុពលដំណាំកៅស៊ូ
- ពុំទាន់មានទីតាំងចម្ការកៅស៊ូបង្ហាញ
- ការគ្រប់គ្រងចម្ការកៅស៊ូតាមប្រព័ន្ធព័ត៌មានវិទ្យា (GIS) ពុំទាន់មាន
- ការផ្តល់មន្ត្រីក្របខណ្ឌមានចំនួនតិចតួចជាងតម្រូវការ ដែលបានស្នើសុំនិងមានសមត្ថភាពពុំឆ្លើយតបទៅនឹងមុខជំនាញ
- ការចូលលួចជ័រក្នុងចម្ការកៅស៊ូកសិឧស្សាហកម្មនៅតែបន្តកើតមាន
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមចម្ការកៅស៊ូកសិឧស្សាហកម្មមួយចំនួនមិនទាន់បានប្រសើរ
- កង្វះកំលាំងពលកម្ម ជាពិសេសអ្នកចៀរជ័រ
- ប្រព័ន្ធព័ត៌មានទីផ្សារកៅស៊ូមិនទាន់បានប្រសើរ
- មណ្ឌលទីផ្សារកៅស៊ូរួមនៅតាមបណ្តាតំបន់មិនទាន់មាន
- មណ្ឌលកែច្នៃកៅស៊ូបង្ហាញរួមនៅតាមបណ្តាតំបន់មិនទាន់មាន។

## ៤. សំណូមពរ

៦០- ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម និងតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍអនុវិស័យកៅស៊ូ ឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព នោះអគ្គនាយកដ្ឋានកៅស៊ូ សូមសំណូមពរមួយចំនួនជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យលទ្ធភាពដោះស្រាយ ដូចខាងក្រោម៖

- សូមការគាំទ្រក្នុងការផ្តល់និងបង្កើនថវិកាតាមកម្មវិធី ដើម្បីបង្កើនសកម្មភាពការងារចុះដល់មូលដ្ឋានចម្ការកៅស៊ូឱ្យបានកាន់តែច្រើនបន្ថែមទៀត
- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតតូបករគតិយុត្តពាក់ព័ន្ធនានា
- ជំរុញកិច្ចសហការរវាងអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- ជំរុញម្ចាស់រោងចក្រសិប្បកម្មបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូឱ្យបានច្រើន ដែលនៅជិតចម្ការកៅស៊ូគ្រួសារ និងផ្តល់ភាពត្រឹមត្រូវក្នុងការថ្លឹង ការគណនារកភាគកៅស៊ូស្ងួត (DRC) តាមរូបមន្តដែលអគ្គ-នាយកដ្ឋានកៅស៊ូបានដាក់ឱ្យអនុវត្ត និងការទូទាត់មានតម្លាភាព

- ជួយផ្តល់បន្ថែមនូវធនធានមនុស្ស សម្ភារប្រើប្រាស់ និងមធ្យោបាយធ្វើដំណើរឱ្យបានគ្រប់គ្រាន់
- ជំរុញឱ្យក្រុមហ៊ុននាំចេញកៅស៊ូ ត្រូវបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់កៅស៊ូយថាប្រភេទកម្ពុជា(CSR)
- ជួយអន្តរាគមន៍ ទៅក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចវិនិយោគលើដំណាំកៅស៊ូទាំងអស់ ឱ្យសហការជាមួយនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីក្តាប់បាននូវស្ថិតិកៅស៊ូ សម្រាប់ធ្វើរបាយការណ៍ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ
- សូមផ្តល់ទីតាំង និងផ្ទៃដីសម្រាប់សាងសង់អនុស្ថានីយពិសោធន៍និងស្រាវជ្រាវដំណាំកៅស៊ូ នៅតាមតំបន់ដែលមានសក្តានុពលសម្រាប់ដំណាំកៅស៊ូ
- ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាកៅស៊ូដល់ម្ចាស់ចម្ការកៅស៊ូ រោងចក្រ សិប្បកម្ម
- ផ្តល់នូវភាពអនុគ្រោះក្នុងការជួសជុលកែលម្អលំនៅដ្ឋានរបស់កម្មករឡើងវិញ ដើម្បីរក្សាសុខមាលភាពរបស់កម្មករនិងបង្កើនប្រសិទ្ធិភាពការងារស្រាវជ្រាវ។

## ៥. សន្និដ្ឋាន

៦១- លទ្ធផលសម្រេចបាននៅក្នុងឆ្នាំ២០១៨នេះ បង្ហាញឱ្យឃើញថា ទោះបីមានការលំបាក និងជួបប្រទះបញ្ហាប្រឈមយ៉ាងណាក៏ដោយ ឈរលើស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងរវាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត និងដោយមានការចូលរួមពីគ្រប់ប្រតិបត្តិករកៅស៊ូ គោលដៅសូចនាករគ្រប់អនុកម្មវិធីនិងចង្កោមសកម្មភាព ត្រូវបានអនុវត្តសម្រេចតាមផែនការដែលបានកំណត់។ ម្យ៉ាងទៀតលទ្ធផលទាំងនេះ មួយចំណែកធំគឺដោយសារការណែនាំពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រី ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ល្អៗ ដោយមានការគាំទ្រទាំងស្មារតី ថវិកា និងបញ្ញាញាណ ដើម្បីឱ្យការអនុវត្តទទួលបាននូវលទ្ធផលជាផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់។

## ៦. ទិសដៅអនុវត្តការងារឆ្នាំ២០១៩

៦២- ដើម្បីសម្រេចបាននូវភារកិច្ចនានាក្នុងឆ្នាំ២០១៩ ស្របតាមយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ លើការលើកស្ទួយវិស័យកសិកម្ម ដើម្បីបង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូមានអនុកម្មវិធីចំនួន៣ ចង្កោមសកម្មភាពចំនួន១២ និងមានទិសដៅដូចខាងក្រោម៖

- ជំរុញផលិតកម្មដំណាំកៅស៊ូនៅឆ្នាំ២០១៩ ឱ្យកើនដល់២៩២,២០៣ាន់តោន ក្នុងកំណើន១៣% ធៀបនឹងឆ្នាំ២០១៨ និងបង្កើនការនាំចេញឱ្យបាន ២៨៣,០៣ាន់តោន
- រក្សាគុណភាពផលិតផលកៅស៊ូល្អក្នុងកម្រិត៧៨% នៃផលិតផលសរុប
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា
- បន្តជំរុញកិច្ចសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអាជ្ញាធរពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស និងទប់ស្កាត់ការបើកស្នាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត

- ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជន និងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- យកចិត្តទុកដាក់ក្នុងការកសាងធនធានមនុស្ស ដោយបំពេញធនធានមនុស្សដែលខ្វះខាត
- បន្តធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិ២០១១-២០២០ ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ឲ្យបានចប់នៅក្នុងឆ្នាំ២០១៩
- បន្តអនុវត្ត និងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៩ ឱ្យបានជោគជ័យតាមចំណុចដៅដែលគ្រោងទុក
- ខិតខំប្រមូលចំណូលឱ្យសម្រេចតាមគោលដៅ
- យកចិត្តទុកដាក់បន្តលើការងារស្រាវជ្រាវ
- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ
- ពង្រឹងការអនុវត្តលើការបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូកែច្នៃ និងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- អនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិ ព្រមទាំងភាគីជាតិដូចជាបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ និងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជីការោងចក្រ មន្ទីរពិសោធន៍
- បន្តចូលរួមសន្និសីទនិងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា
- បន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យកៅស៊ូ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពី ការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តសុំបង្កើតទីតាំងអនុស្ថានីយនិងមន្ទីរពិសោធន៍បន្ថែម និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយនិងបង្ហាញ
- ជំរុញការចងក្រងនិងពង្រឹងសហគមន៍កៅស៊ូគ្រួសារ
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- ជំរុញស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារទាំងអស់ ឱ្យមានលិខិតអនុញ្ញាតត្រឹមត្រូវ
- ពង្រីកនិងកៀងគររកដៃគូសហប្រតិបត្តិការក្នុងការផ្តល់ប្រភពថវិកានិងបច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍកៅស៊ូគ្រួសារ៕

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

## រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ

(យោងអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨)



ឧបសម្ព័ន្ធទី២

# លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨

| ឈ្មោះចង្កោមសកម្មភាព | ថវិកា ( លានរៀល ) | | | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | គ្រោង | ចំណាយ | ភាគរយ | ឈ្មោះ | គោលដៅ | សម្រេច | % | |
| **សរុបរួម** | ៦ ៦២០,៤ | ៦ ៤៥២,៩ | ៩៧,៥ | | | | | |
| **បន្ទុកបុគ្គលិក** | ៣ ២៣៤,២ | ៣ ២៣២,៥ | ៩៩,៩ | | | | | |
| **ក្រៅបន្ទុកបុគ្គលិក** | ៣ ៣៨៦,២ | ៣ ២២០,៤ | ៩៥,១ | | | | | |
| អនុកម្មវិធីទី៥៖ ជំរុញការអភិវឌ្ឍកៅស៊ូ ធម្មជាតិ ប្រកបដោយ និរន្តរភាព | ៦៩៣,៥ | ៦៧២,៦ | ៩៧ | ផលិតផលកៅស៊ូ (%) | ១៥ | ១៣,៨៧ | ៩២,៤៧ | |
| | | | | គុណភាពផលិតផល (%) | ៧៨ | ៧៨ | ១០០ | |
| ១.៥.១-ផ្ទេរបច្ចេកវិទ្យាដាំណាំកៅស៊ូដល់កសិករកៅស៊ូ គ្រួសារ និងមន្ត្រីបង្គោល | ៣១៥,៤ | ៣១៣,៤ | ៩៩,៤ | ចំនួនកសិករចូលរួម (នាក់) | ៨១៥ | ៨៤៨ | ១០៤.១ | |
| | | | | ចំនួនមន្ត្រីចូលរួម (នាក់) | ៣៥ | ៣៥ | ១០០ | |
| ១.៥.២-ចងក្រង និងពង្រឹងសហគមន៍កសិកម្មកៅស៊ូ គ្រួសារ | ១៧១,៤ | ១៦៧,៧ | ៩៧,៩ | ចំនួនសហគមន៍បង្កើត(សហគមន៍) | ៣ | ៣ | ១០០ | |
| | | | | ចំនួនសហគមន៍ពង្រឹង(សហគមន៍) | ៦ | ៥ | ៨៣.៣ | |
| ១.៥.៣-ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃ ដល់ប្រតិបត្តិករកៅស៊ូ | ៩៤,៤ | ៨០,២ | ៨៤,៩ | ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ៥០០ | ៥២១ | ១០៤.២ | |
| ១.៥.៤-បណ្តុះបណ្តាល និងផ្សព្វផ្សាយពីទីផ្សារកៅស៊ូ | ១១២,៣ | ១១១,៣ | ៩៩ | ចំនួនកសិករ (នាក់) | ៣៥០ | ៣៦៩ | ១០៥.៤ | |
| | | | | ចំនួនព្រឹត្តិបត្រកៅស៊ូ (ច្បាប់) | ២១៦០ | ២១៦០ | ១០០ | |

| ឈ្មោះចង្កោមសកម្មភាព | ថវិកា ( លានរៀល ) | | | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | គ្រោង | ចំណាយ | ភាគរយ | ឈ្មោះ | គោលដៅ | សម្រេច | % | |
| អនុកម្មវិធីទី១.៦៖ ពង្រឹងការរៀបចំនិងការអនុវត្តផែនការវិស័យកៅស៊ូ | ១ ៤២២,៧ | ១ ៣៦១,២ | ៩៥,៧ | ប្រសិទ្ធភាពនៃការអនុវត្តថវិកា (%) | ៩៥ | ៩៧,៨២ | ១០២,៩៧ | |
| | | | | ចំនួនប្រតិបត្តិករកៅស៊ូទទួលបានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត (នាក់) | ៤៥០ | ៤៥០ | ១០០ | |
| ១.៦.១-តាមដានវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព | ៩០,៩ | ៩០,៥ | ៩៩,៥ | ចំនួនសិក្ខាសាលា (លើក) | ១ | ១ | ១០០ | |
| | | | | ចំនួនចុះតាមដាន(លើក) | ៨ | ៨ | ១០០ | |
| ១.៦.២-តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគដីសម្បទានសេដ្ឋកិច្ចលើវិស័យកៅស៊ូ | ១៩៥,១ | ១៩២,៩ | ៩៨,៩ | ចំនួនចុះតាមដាន(លើក) | ១១ | ១១ | ១០០ | |
| | | | | ចំនួនសិក្ខាសាលា(លើក) | ២ | ២ | ១០០ | |
| ១.៦.៣-គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំ | ១ ០២៤ | ៩៦៧,៤ | ៩៤,៥ | ចំនួនប្រជុំបូកសរុបប្រចាំឆ្នាំ(លើក) | ១ | ១ | ១០០ | |
| ១.៦.៤-ប្រជុំរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ | ១០២,៨ | ១០១,១ | ៩៨,៣ | ចំនួនប្រជុំក្រុមការងារ(លើក) | ២៨ | ២៦ | ៩២.៩ | |
| | | | | ចំនួនប្រតិបត្តិករកៅស៊ូ(នាក់) | ៤៥០ | ៤៥០ | ១០០ | |
| ១.៦.៥-បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ | ៩,៩ | ៩,៤ | ៩៥ | ចំនួនមន្ត្រី(នាក់) | ៤០ | ៤០ | ១០០ | |
| អនុកម្មវិធីទី១.៧៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មីនិងប្រសិទ្ធិភាពគុណភាពផលិតផលកៅស៊ូកម្ពុជា | ១ ២៧០ | ១ ១៨៦,៦ | ៩៣,៤ | អត្រា (%) នៃការត្រួតពិនិត្យនិងវាយតម្លៃច្បារពូជ | ២៥ | ២៥ | ១០០ | |
| | | | | អត្រា(%)នៃការចុះត្រួតពិនិត្យនិងវាយតម្លៃរោង ចក្រកៅស៊ូ | ២ | ២ | ១០០ | |

| ឈ្មោះចង្កោមសកម្មភាព | ថវិកា ( លានរៀល ) | | | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|---|---|---|
| | គ្រោង | ចំណាយ | ភាគរយ | ឈ្មោះ | គោលដៅ | សម្រេច | % | |
| ១.៧.១-ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ | ៥៧២,៨ | ៥៧២,៨ | ១០០ | ច្បារបង្កាត់ពូជថ្មី (ពូជ/វដ្ដ) | ១៩ | ១៩ | ១០០ | |
| | | | | ពិសោធន៍ទ្រង់ទ្រាយធំ (ក្លូន) | ៥៣ | ៥៣ | ១០០ | |
| | | | | តាមដានចំការពិសោធន៍ (តំបន់) | ៥ | ៥ | ១០០ | |
| | | | | អនុសាសន៍ប្រើប្រាស់ជី (ហិកតា) | ២០ | ២០ | ១០០ | |
| | | | | អនុសាសន៍បហរព័ន្ធស្រោចស្រព (ហិកតា) | ១២ | ១២ | ១០០ | |
| | | | | តាមដានចំការពិសោធន៍(ហិកតា) | ២២០,៤ | ២២០,៤ | ១០០ | |
| ១.៧.២-ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ | ២៥៥ | ២៥៥ | ១០០ | តាមដានប្រព័ន្ធមុខចៀរ(ចំការ/ឆ្នាំ) | ២ | ២ | ១០០ | |
| | | | | វិភាគសរីរៈទឹកជ័រ (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| | | | | ពិសោធន៍ជាមួយ IRA (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| | | | | ពិសោធន៍ក្នុងប្រទេស (ដង/ឆ្នាំ) | ៤ | ៤ | ១០០ | |
| | | | | ត្រួតពិនិត្យរោងចក្រ (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| ១.៧.៣-ទទួលធ្វើសាវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទានIRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ | ៤៤២,២ | ៣៥៨,៨ | ៨១,១ | ដំណើរការទូទៅរបស់វិទ្យាស្ថាន | | | | |

ឧបសម្ព័ន្ធទី៣

# គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៩

| បរិយាយ | ថវិកាអនុម័ត (លានរៀល) | | | សូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | |
|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ភាគរយ | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | មូលហេតុនៃការប្រែប្រួល |
| **សរុបរួម** | ៦ ៦២០,៤ | ៧ ២៦៧,៥ | ១០៩,៨ | | | | |
| **បន្ទុកបុគ្គលិក** | ៣ ២៣៤,២ | ៣ ២៨៣,៣ | ១០១,៥ | | | | |
| **ក្រៅបន្ទុកបុគ្គលិក** | ៣ ៣៨៦,២ | ៣ ៩៨៤,២ | ១១៧,៧ | | | | |
| អនុកម្មវិធីទី១.៥៖ ជំរុញការអភិវឌ្ឍន៍កៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព | ៦៩៣,៥ | ៦៩៣,៥ | ១០០ | ផលិតផលកៅស៊ូ (តោន) | ២២២ ៤០០ | ២៩២ ០០០ | |
| | | | | គុណភាពកៅស៊ូ (ភាគរយ) | ៧៨ | ៧៨ | |
| ១.៥.១-ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ និងមន្ត្រីបង្គោល | ៣១៥,៤ | ៣៣៨,៦ | ១០៧,៤ | ចំនួនកសិករចូលរួម | ៨១៥ | ៨១៥ | |
| | | | | ចំនួនមន្ត្រីបង្គោលចូលរួម | ៣៥ | ៤០ | |
| ១.៥.២-ចងក្រង និងពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ | ១៧១,៤ | ១៤៨,២ | ៨៦,៥ | ចំនួនសហគមន៍ដែលបានចុះពង្រឹង | ៧ | ៧ | |
| | | | | ចំនួនសហគមន៍ចុះចងក្រង | ៣ | ៣ | |
| ១.៥.៣-ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ | ៩៤,៤ | ៩៤,៤ | ១០០ | ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ៥០០ | ៦៦០ | |
| ១.៥.៤-បណ្តុះបណ្តាលនិងផ្សព្វផ្សាយពីទីផ្សារកៅស៊ូ | ១១២,៣ | ១១២,៣ | ១០០ | ចំនួនសិក្ខាកាម (នាក់) | ៣៥០ | ៣៥០ | |
| | | | | ចំនួនព្រឹត្តិបត្រកៅស៊ូ (ច្បាប់) | ២.១៦០ | ២.១៦០ | |

| បរិយាយ | ថវិកាអនុម័ត (លានរៀល) | | | សូចនាករ លទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | |
|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ភាគរយ | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | មូលហេតុនៃការប្រែប្រួល |
| អនុកម្មវិធីទី៦៖ ពង្រឹងការរៀបចំនិងការអនុវត្តផែនការវិស័យកៅស៊ូ | ១ ៤២២,៧ | ១ ៤២០,៧ | ៩៩,៩ | អត្រាថវិកាត្រូវបានអនុវត្ត (%) | ៩៥ | ៩៥ | |
| | | | | ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ៤៥០ | ៤៥០ | |
| ១.៦.១-តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព | ៩០,៩ | ១០២,២ | ១១២,៤ | ចំនួនសិក្ខាកាមរៀបចំគម្រោងថវិកាកម្មវិធី (នាក់) | ១ | ៤០ | ប្តូរសូចនាករពីចំនួនសិក្ខាសាលាទៅជាចំនួនសិក្ខាកាម |
| | | | | ចំនួនចុះពិនិត្យតាមដាននិងវាយតម្លៃ | ៨ | ៨ | |
| ១.៦.២-តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូ | ១៩៥,១ | ១៨៤,២ | ៩៤,៤ | ចំនួនចុះ (លើក) | ១១ | ១០ | |
| | | | | ចំនួនសិក្ខាកាម (នាក់) | ២ | ៨៥ | |
| ១.៦.៣-គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកការងារ | ១ ០២៤ | ១០៣១,២ | ១០០,៧ | | | | |
| ១.៦.៤-ផ្សព្វប្រជុំរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ | ១០២,៨ | ៩២,៩ | ៩០,៤ | ចំនួនប្រជុំក្រុមការងារ (លើក) | ២៨ | ២៤ | |
| | | | | ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ៤៥០ | ៤៥០ | |
| ១.៦.៥-បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ | ៩,៩ | ១០,២ | ១០៣ | ចំនួនសិក្ខាកាម (នាក់) | ៤០ | ៤៥ | |
| អនុកម្មវិធីទី១.៧៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មីនិងប្រសិទ្ធិភាពគុណភាពផលិតផលកៅស៊ូកម្ពុជា | ១ ២៧០ | ១ ៨៧០ | ១៤៧,២ | អត្រា (%) នៃការត្រួតពិនិត្យនិងវាយតម្លៃច្បារពូជ | ២៥ | ២៥ | |
| | | | | អត្រា (%) នៃការចុះត្រួតពិនិត្យនិងវាយតម្លៃរោងចក្រកៅស៊ូ | ២ | ២ | |

| បរិយាយ | ថវិកាអនុម័ត ( លានរៀល ) | | | សូចនាករ លទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | |
|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ភាគរយ | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | មូលហេតុនៃការប្រែប្រួល |
| ១.៧.១-ការអភិរក្សនិងអភិវឌ្ឍន៍ក្លូនកៅស៊ូ ហើយនិងការសិក្សាអនុវត្តកសិកម្មល្អក្នុងការដាំដុះ និងថែទាំកៅស៊ូ | ៥៧២,៨ | ៦០០ | ១០៤,៧ | ច្បារបង្កាត់ពូជថ្មី (ពូជ/វដ្ត) | ១៩ | ១៩ | |
| | | | | ពិសោធន៍ទ្រង់ទ្រាយធំ (ក្លូន) | ៥៣ | ៥៣ | |
| | | | | តាមដានចំការពិសោធន៍ (តំបន់) | ៥ | ៥ | |
| | | | | អនុសាសន៍ប្រើប្រាស់ជី (ហិកតា) | ២០ | ២០ | |
| | | | | អនុសាសន៍បហារព័ន្ធស្រោចស្រព (ហិកតា) | ១២ | ១២ | |
| | | | | តាមដានចំការពិសោធន៍ (ហិកតា) | ២២០.៤ | ២២០.៤ | |
| ១.៧.២-ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាពនិងការពង្រឹងគុណភាពផលិតផលកៅស៊ូ | ២៥៥ | ២៥៥ | ១០០ | តាមដានប្រព័ន្ធមុខចៀរ (ចំការ/ឆ្នាំ) | ២ | ២ | |
| | | | | វិភាគសរីរៈទឹកជ័រ (ដង/ឆ្នាំ) | ២ | ២ | |
| | | | | ពិសោធន៍ជាមួយ IRA (ដង/ឆ្នាំ) | ២ | ២ | |
| | | | | ពិសោធន៍ក្នុងប្រទេស (ដង/ឆ្នាំ) | ៤ | ៤ | |
| | | | | ត្រួតពិនិត្យរោងចក្រ (ដង/ឆ្នាំ) | ២ | ២ | |
| ១.៧.៣-គាំទ្រដំណើរការពិសោធន៍ស្រាវជ្រាវ | ៤៤២,២ | ១ ០១៥ | ២៩៩,៥ | ដំណើរកាទូទៅរបស់វិទ្យាស្ថាន | | | |

# ស្ថិតិ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ១៩៨០-២០១៨

| ឆ្នាំ | សរុបផ្ទៃដី (ហិកតា) | ផ្ទៃដីចៀរ (ហិកតា) | ផលិតផល (តោន) | ទិន្នផល (គ.ក្រ/ហ.ត/ឆ្នាំ) | នាំចេញ (តោន) | ទឹកប្រាក់នាំចេញ (ដុល្លារ) |
|---|---|---|---|---|---|---|
| 1980 | 5,000 | 5,000 | 1,300 | 260 | 1,454 | |
| 1981 | 8,800 | 8,800 | 4,000 | 455 | 2,616 | |
| 1982 | 11,800 | 11,800 | 7,000 | 593 | 8,000 | |
| 1983 | 14,546 | 14,546 | 9,000 | 619 | 10,021 | |
| 1984 | 19,506 | 19,506 | 13,388 | 686 | 13,307 | |
| 1985 | 26,300 | 26,300 | 17,645 | 671 | 16,421 | |
| 1986 | 35,779 | 35,779 | 24,497 | 685 | 23,280 | |
| 1987 | 40,000 | 40,000 | 24,917 | 623 | 26,335 | |
| 1988 | 41,500 | 41,500 | 31,380 | 756 | 29,968 | |
| 1989 | 46,789 | 46,789 | 33,645 | 719 | 33,727 | |
| 1990 | 51,160 | 51,122 | 34,700 | 679 | 25,563 | |
| 1991 | 51,670 | 51,570 | 35,000 | 679 | 24,807 | |
| 1992 | 50,835 | 50,709 | 28,364 | 559 | 26,645 | |
| 1993 | 43,545 | 43,334 | 22,345 | 516 | 20,990 | |
| 1994 | 42,817 | 42,576 | 30,585 | 718 | 30,742 | |
| 1995 | 45,048 | 44,523 | 35,427 | 796 | 34,413 | |
| 1996 | 45,538 | 44,400 | 43,891 | 989 | 41,607 | |
| 1997 | 44,466 | 43,499 | 43,503 | 1,000 | 44,799 | |
| 1998 | 42,625 | 41,464 | 41,398 | 998 | 39,966 | |
| 1999 | 38,413 | 37,358 | 44,043 | 1,179 | 43,221 | |
| 2000 | 53,722 | 42,698 | 42,007 | 984 | 40,066 | |
| 2001 | 51,458 | 37,680 | 38,562 | 1,023 | 35,672 | |
| 2002 | 55,582 | 36,773 | 32,384 | 881 | 36,774 | |
| 2003 | 53,527 | 33,696 | 32,382 | 961 | 32,764 | |
| 2004 | 54,209 | 31,590 | 33,770 | 1,069 | 33,558 | |
| 2005 | 60,406 | 30,402 | 29,464 | 969 | 29,950 | |
| 2006 | 69,994 | 32,390 | 32,077 | 990 | 31,184 | |
| 2007 | 82,059 | 30,491 | 32,975 | 1,081 | 33,121 | 60,482,808 |
| 2008 | 107,901 | 34,313 | 37,050 | 1,080 | 36,000 | 58,320,000 |
| 2009 | 127,723 | 34,135 | 37,380 | 1,095 | 36,500 | 65,963,868 |
| 2010 | 181,433 | 38,406 | 42,250 | 1,100 | 42,000 | 111,510,000 |
| 2011 | 213,104 | 45,163 | 51,339 | 1,137 | 44,969 | 192,288,956 |
| 2012 | 280,355 | 55,361 | 64,525 | 1,166 | 59,917 | 174,760,129 |
| 2013 | 328,771 | 78,493 | 85,244 | 1,086 | 86,052 | 189,408,732 |
| 2014 | 357,809 | 90,545 | 97,054 | 1,072 | 100,151 | 154,160,799 |
| 2015 | 388,955 | 111,232 | 126,861 | 1,141 | 128,047 | 154,001,151 |
| 2016 | 432,735 | 126,996 | 145,200 | 1,143 | 145,100 | 187,164,551 |
| 2017 | 436,339 | 170,230 | 193,286 | 1,135 | 188,832 | 299,394,841 |
| 2018 | 436,682 | 201,949 | 220,100 | 1,090 | 217,500 | 286,944,528 |

ឧបសម្ព័ន្ធទី៥

# ស្ថានភាពការងារអាជីវកម្ម ផលិតកម្ម និងនីហរ័ណកម្មកៅស៊ូ ឆ្នាំ២០១៨

| បរិយាយ | | ផ្ទៃដី (ហិកតា) | | | ផលិតផលកៅស៊ូស្ងួត (តោន) | | | នីហរ័ណកម្មកៅស៊ូស្ងួត | | តម្លៃលក់ | ទិន្នផល | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចៀរជ័រ | ថែទាំ | សរុប | ក្រុមហ៊ុន | គ្រួសារ | សរុប | បរិមាណ (T) | ទឹកប្រាក់ (USD) | មធ្យម($/T) | Kg/ha/ឆ្នាំ | |
| **១.ចម្ការកៅស៊ូកសិ -ឧស្សាហ កម្ម (ក+ខ)** | | **82 113** | **193 467** | **275 579** | **90 590** | **0** | **90 590** | **89 029** | **117 785 200** | **1 323** | **1 103** | |
| **ក. -ចម្ការកៅស៊ូកសិ -ឧស្សាហ កម្ម (អវិនិយោគ )** | | **37 191** | **13 822** | **51 012** | **42 392** | **0** | **42 392** | **42 929** | **56 969 656** | **1 327** | **1 140** | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 802 | 538 | | 538 | 550 | 659 500 | 1 199 | 803 | |
| ២ | សុភក្តិនីកា អ៊ីនវេសមេន គ្រុប (ជុប,ទំរីង) | 12 310 | 2 870 | 15 180 | 15 918 | | 15 918 | 16 906 | 23 030 051 | 1 362 | 1 293 | |
| ៣ | ចម្ការកៅស៊ូតាប៉ាវ | 1 191 | 914 | 2 105 | 1 616 | | 1 616 | 1 575 | 2 031 750 | 1 290 | 1 357 | |
| ៤ | ចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 5 631 | 2 809 | 8 440 | 4 403 | | 4 403 | 4 655 | 6 455 274 | 1 387 | 782 | |
| ៥ | ស៊ីហ្វ វ៉ាប់ប៉ើរ លីមីធីត (រតនគិរី) | 79 | 2 588 | 2 667 | 136 | | 136 | 347 | 428 864 | 1 236 | 1 719 | |
| ៦ | ស៊ីហ្វ រីសេសស៍ លីមីធីត (ស្នួល) | 3 859 | 548 | 4 407 | 4 603 | | 4 603 | 4 961 | 6 235 683 | 1 257 | 1 193 | |
| ៧ | ឡុងស្រេង អ៊ីនធើណេសិនណល់ (បឹងកេត) | 3 343 | 843 | 4 186 | 5 251 | | 5 251 | 4 723 | 6 364 875 | 1 348 | 1 571 | |
| ៨ | ក្រុមហ៊ុន អាន ម៉ាឌី គ្រុប (ចម្ការអណ្តូង) | 3 848 | 1 415 | 5 263 | 2 666 | | 2 666 | 2 498 | 3 019 560 | 1 209 | 693 | |
| ៩ | ក្រុមហ៊ុន អាន ម៉ាឌី គ្រុប (ពាមជាំង-រមាសហែក) | 1 901 | 1 265 | 3 166 | 1 430 | | 1 430 | 1 352 | 1 608 240 | 1 190 | 752 | |
| ១០ | ក្រុមហ៊ុន គ្រែក (ខេមបូឌា) ខូ អិលធីឌី | 4 359 | 439 | 4 798 | 5 832 | | 5 832 | 5 361 | 7 135 860 | 1 331 | 1 338 | |
| **ខ--ចម្ការកៅស៊ូវិនិយោគ លើ សម្បទាន ដីសេដ្ឋកិច្ច** | | **44 922** | **179 645** | **224 567** | **48 198** | | **48 198** | **46 100** | **60 815 544** | **1 319** | **1 073** | |
| | ចំនួន១២៨ ក្រុមហ៊ុន | 44 922 | 179 645 | 224 567 | 48 198 | | 48 198 | 46 100 | 60 815 544 | 1 319 | 1 073 | |
| **២--ចម្ការកៅស៊ូ គ្រួសារ** | | **119 837** | **41 266** | **161 103** | | **129 510** | **129 510** | **128 471** | **169 159 328** | **1 317** | **1 081** | |
| | ចំនួន២០ខេត្ត | 119 837 | 41 266 | 161 103 | | 129 510 | 129 510 | 128 471 | 169 159 328 | 1 317 | 1 081 | |
| សរុប (១+២) | | **201 950** | **234 733** | **436 682** | **90 590** | **129 510** | **220 100** | **217 500** | **286 944 528** | **1 319** | **1 090** | |

ឧបសម្ព័ន្ធទី៦

# ស្ថិតិជំណាំកៅស៊ូឆ្នាំ២០១៨

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ (ហិកតា) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | 612,207 | 82,112 | 193,467 | 275,579 |
| | **ក-អតីតចម្ការកៅស៊ូរដ្ឋនិងទសកកក** | **ខេត្ត** | 61,501 | 37,190 | 13,822 | 51,012 |
| 1 | សុភក្តិនីកា អិនវេសមេន គ្រុប (ជុប) | ត្បូងឃ្មុំ+កំ.ធំ | 17,405 | 12,310 | 2,870 | 15,180 |
| 2 | អាន ម៉ាឌី គ្រុប(ពាមជាំង) | ត្បូងឃ្មុំ | 3,947 | 1,901 | 1,265 | 3,166 |
| 3 | ក្រែក(ខេមបូឌា) ខូអិលធីឌី(ក្រែក) | ត្បូងឃ្មុំ | 5,116 | 4,359 | 439 | 4,798 |
| 4 | ចម្ការកៅស៊ូមេមត់ | ត្បូងឃ្មុំ | 9,051 | 5,631 | 2,809 | 8,440 |
| 5 | ចម្ការកៅស៊ូ តាប៉ាវ | ត្បូងឃ្មុំ | 3,244 | 1,191 | 914 | 2,105 |
| 6 | អាន ម៉ាឌី គ្រុប(ចម្ការអណ្តូង) | កំពង់ចាម | 6,956 | 3,848 | 1,415 | 5,263 |
| 7 | ឡុងស្រេងអ៊ិនធឺណេស៊ិនណល (បឹងកេត) | កំពង់ចាម | 6,353 | 3,343 | 843 | 4,187 |
| 8 | ស្វីហ្វសែសស៍លីមីធីត(ស្នួល) | ក្រចេះ | 4,807 | 3,859 | 548 | 4,406 |
| 9 | ស្វីហ្វវ៉ាប់ប៊ើរលីមីធីត(ឡាបានសៀក) | រតនគិរី | 3,589 | 79 | 2,588 | 2,666 |
| 10 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ត្បូងឃ្មុំ | 1,033 | 670 | 132 | 801 |
| | **ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច** | **ខេត្ត** | 550,706 | 44,922 | 179,645 | 224,567 |
| 1 | Green Sea Agriculture co.,LTD.(MRT) | ស្ទឹងត្រែង | 6,250 | | 349 | 349 |
| 2 | សុភក្តិនីកា អ៊ីនវេសមេន អាគ្រូ អ៊ិនដាសស្ទ្រៀល ផ្លេន ខូ អិលធីឌី | ស្ទឹងត្រែង | 10,000 | 593 | 4,215 | 4,808 |
| 3 | សល សុភា ពាណិជ្ជ ខូ អិលធីឌី | ស្ទឹងត្រែង | 9,917 | 700 | 3,770 | 4,470 |
| 4 | ស៊ីវ ហ្គេច អិនវេសមេន ខូ អិលធីឌី | ស្ទឹងត្រែង | 10,000 | | 1,524 | 1,524 |
| 5 | ភូម៉ាឌី អិនវេសមេន គ្រុប ខូ អិលធីឌី | ស្ទឹងត្រែង | 10,000 | 98 | 2,502 | 2,600 |
| 6 | ហូលឡី អ៊ីខូ អ៊ីនដាសស្ទៀល (ខេមបូឌា) ខូ អិលធីឌី | រតនគិរី | 7,118 | | 50 | 50 |
| 7 | ម្កុដ ពេជ្រ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 1,950 | | 850 | 850 |
| 8 | JING ZHON RI ខូ អិលធីឌី | រតនគិរី | 9,224 | | 190 | 190 |
| 9 | កៅស៊ូ អេលែរ ប៊ីអឹម យ៉ាញស្តុក ខូ អិលធីឌី | រតនគិរី | 1,425 | | 1,284 | 1,284 |
| 10 | ហ៊ាង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | 6,102 | 1,207 | 4,575 | 5,782 |
| 11 | គីរី អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 661 | 15 | 620 | 635 |
| 12 | ក្រុង ប៊ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | 6,051 | 60 | 5,561 | 5,621 |
| 13 | ហេង ប្រាឌ័រ ខូ អិលធីឌី | រតនគិរី | 1,961 | 850 | 1,031 | 1,881 |
| 14 | ស៊ី អ ឌី ខូ អិលធីឌី | រតនគិរី | 3,284 | 21 | 3,119 | 3,140 |
| 15 | ហ៊ាង អាន អូរយ៉ាដាវ ខូ អិលធីឌី | រតនគិរី | 3,129 | | 3,082 | 3,082 |
| 16 | វាសនា អ៊ិនវេសមេន | រតនគិរី | 1,764 | 130 | 1,412 | 1,542 |
| 17 | ជាំងលី (អ៊ិនវេសមេន) ខូ អិលធីឌី | រតនគិរី | 1,900 | | 314 | 314 |
| 18 | ឌី អឹម គ្រុប ខូអិលធីឌី | រតនគិរី | 749 | | 190 | 190 |
| 19 | ៧ មករា ដារី ខូ អិលធីឌី (ហេងអភិវឌ្ឍន៍) | រតនគិរី | 8,655 | | 205 | 205 |
| 20 | នុភាព សុភី អ៊ិនវេសមេន ខូ អិលធីឌី | រតនគិរី | 9,000 | | 490 | 490 |
| 21 | មិត្តភាព ម៉ែន សារុន ខូ អិលធីឌី | រតនគិរី | 1,330 | | 835 | 835 |
| 22 | ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 914 | 50 | 519 | 569 |
| 23 | ផេស៊ីហ្វិក ឡូធើស យ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,014 | | 2,417 | 2,417 |
| 24 | ផេស៊ីហ្វិក ភើល យ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,614 | | 2,540 | 2,540 |
| 25 | ផេស៊ីហ្វិក ប្រាយដ៍ យ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,773 | | 4,817 | 4,817 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ(ហិកតា) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថៃទាំ | សរុប |
| 26 | ផេស៊ីហ្វិក ប្រេ្គន យ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,656 | | 1,988 | 1,988 |
| 27 | ឌី ធី ស៊ី គ្រុប ខូ អិលធីឌី | មណ្ឌលគិរី | 5,704 | 18 | 127 | 145 |
| 28 | កូវីផាម៉ា ខូ អិលធីឌី | មណ្ឌលគិរី | 5,345 | | 3,217 | 3,217 |
| 29 | សេដ្ឋីកូលា | មណ្ឌលគិរី | 4,273 | 950 | 1,293 | 2,243 |
| 30 | ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) ខូ អិលធីឌី | មណ្ឌលគិរី | 500 | | 132 | 132 |
| 31 | វ៉ាក់ណាស៊ី | មណ្ឌលគិរី | 2,705 | 1,800 | | 1,800 |
| 32 | ដាក់ ឡាក់ មណ្ឌលគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | មណ្ឌលគិរី | 1,816 | 1,226 | 195 | 1,421 |
| 33 | វី ឡា ឌីវេឡុបមេន ខូ អិលធីឌី | មណ្ឌលគិរី | 728 | | 479 | 479 |
| 34 | ប៊ិញហ្វឿក ក្រចេះរ៉ាប់បើរ១ ខមភេនី លីមីធីត | មណ្ឌលគិរី | 4,291 | | 3,451 | 3,451 |
| 35 | លែន & ឌីវេលឡុបភីង (ខេមបូឌា) ខូ អិលធីឌី | មណ្ឌលគិរី | 7,000 | | 900 | 900 |
| 36 | ដុងភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (៣គំរោង) | ក្រចេះ | 8,461 | 2,206 | 4,185 | 6,391 |
| 37 | ដុងណាយ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | 6,524 | 2,300 | 3,855 | 6,155 |
| 38 | ញូ ឡាញ ខេម ភីធីវ៉ាយ អិលធីឌី | ក្រចេះ | 8,461 | | 863 | 863 |
| 39 | អេហ្គ្រី អ៊ិនដាសស្រ្ទៀល គ្រុប ឌីវេឡុបមេន (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | 7,000 | | 580 | 580 |
| 40 | គ្រុប & លែន ឌីវេឡុបមែន (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | 7,200 | | 425 | 425 |
| 41 | ស៊ុន គុយ ទី អ៊ីមផត & អ៊ិចផត | ក្រចេះ | 903 | | 75 | 75 |
| 42 | ហ្វ្រិន អាយលែន អេហ្គ្រីខលឈើរ័ល ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | 8,180 | | 1,624 | 1,624 |
| 43 | ស៊ី អេច ភី ប៊ី ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | 8,686 | | 409 | 409 |
| 44 | ឈុន ហុង រ៉ាប់ប៊ើរ បេតធើរ ខូ អិលធីឌី | ក្រចេះ | 7,764 | | 3,884 | 3,884 |
| 45 | ភូរៀង ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | 5,831 | 160 | 5,307 | 5,467 |
| 46 | ដូវទីសាយហ្គន- ប៊ីញហ្វឿក (អេស ប៊ី ខេ) ខូ អិលធីឌី | ក្រចេះ | 6,436 | | 2,634 | 2,634 |
| 47 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ស្វាយជ្រះ) | ក្រចេះ | 882 | 160 | 559 | 719 |
| 48 | ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រារូខូ) | ក្រចេះ | 2,060 | 150 | 1,846 | 1,996 |
| 49 | ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ) | ក្រចេះ | 2,550 | | 2,307 | 2,307 |
| 50 | ច័ន្ទ សុភា អភិវឌ្ឍន៍ ខូ អិលធីឌី | ក្រចេះ | 5,088 | | 467 | 467 |
| 51 | ហឺរ៉ាយស្សិន អេហ្គ្រីខលឈើរ ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | 9,996 | | 300 | 300 |
| 52 | សុវណ្ណ វុទ្ធី ខូ អិលធីឌី | ក្រចេះ | 5,000 | | 1,192 | 1,192 |
| 53 | ប៊ីញហ្វឿក ក្រចេះ រ៉ាប់ប៊ើរ ២ ខមភេនី លីមីធីត | ក្រចេះ | 4,940 | | 4,391 | 4,391 |
| 54 | អ៊ីសធើន រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | 4,868 | | 4,275 | 4,275 |
| 55 | សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី | ក្រចេះ | 1,225 | 200 | 676 | 876 |
| 56 | ត្រាចញៀម ហ៊ូហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា | ក្រចេះ | 2,248 | 341 | 1,198 | 1,539 |
| 57 | E-Investment (Cambodia) Ltd | ក្រចេះ | 5,828 | 700 | 1,400 | 2,100 |
| 58 | ចម្ការកៅស៊ូ មេមត់ ខូ អិលធីឌី | ក្រចេះ | 9,855 | | 1,019 | 1,019 |
| 59 | វៀតណាម កម្ពុជា Economy Trade and Industry | ក្រចេះ | 4,381 | 244 | 3,600 | 3,844 |
| 60 | សាយឌុង កៅស៊ូ ឌុកឌុង ខូ អិលធីឌី | ក្រចេះ | 1,621 | 237 | 1,263 | 1,499 |
| 61 | សុវណ្ណរាជសីហ៍ ខូ អិលធីឌី | ក្រចេះ | 2,867 | 320 | 1,730 | 2,050 |
| 62 | ថេរវិនិយោគ | ក្រចេះ | 520 | 109 | 259 | 368 |
| 63 | ជី ភី អ៊ី | ក្រចេះ | 678 | 21 | 208 | 229 |
| 64 | រតនៈស្មោន ខេមបូឌា ខូ អិលធីឌី | ក្រចេះ | 479 | 323 | 28 | 351 |
| 65 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ធ្នូ) | ក្រចេះ | 609 | | 497 | 497 |
| 66 | ខេមបូ ហា យ៉ុង វិនិយោគ កសិ-ឧស្សាហកម្ម | ក្រចេះ | 701 | 50 | 300 | 350 |
| 67 | ប៊ីជីម៉ិចកូ សុធី អភិវឌ្ឍន៍ ខូ អិលធីឌី | ត្បូងឃ្មុំ | 980 | 150 | 305 | 455 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ(ហិកតា) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| 68 | ក្រុមហ៊ុន ថារី អភិវឌ្ឍន៍ ខូ អិលធីឌី | ត្បូងឃ្មុំ | 832 | 350 | 477 | 827 |
| 69 | ហេង ផៃអឹម អភិវឌ្ឍន៍ ខូ អិលធីឌី | ត្បូងឃ្មុំ | 600 | | 450 | 450 |
| 70 | ហេង សុខងន់ វិនិយោគ ខូ អិលធីឌី | ត្បូងឃ្មុំ | 833 | 190 | 283 | 473 |
| 71 | ម៉ែន សារុន អាហារ័ណ នីហារ័ណ | ត្បូងឃ្មុំ | 4,400 | 325 | 375 | 700 |
| 72 | ប៊ី អិន អេ (ខេម) ខប | កំពង់ធំ | 7,500 | | 2,529 | 2,529 |
| 73 | ហ្វាម៉ា អ៊ីនវេសមេន ខូ អិលធីឌី | កំពង់ធំ | 938 | | 107 | 107 |
| 74 | ឫទ្ធិមុនី សំណាងលាភ ខូ អិលធីឌី | កំពង់ធំ | 1,678 | | 1,623 | 1,623 |
| 75 | ហ្គោល ហ្វ៊ូយសុន (ខេមបូឌា) អេ/ស៊ី អ៊ីមផត អិចផត & ខនស្រ្តាកសិន ខូ អិលធីឌី | កំពង់ធំ | 3,371 | 2,200 | 874 | 3,074 |
| 76 | ស៊ី ស៊ី វី ខូ អិលធីឌី | កំពង់ធំ | 2,014 | 359 | 1,569 | 1,928 |
| 77 | តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 7,767 | 6,633 | 605 | 7,239 |
| 78 | ប៉ារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 5,293 | 4,959 | 435 | 5,394 |
| 79 | ភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 8,694 | 2,691 | 4,973 | 7,664 |
| 80 | ទេពី អាគ្រូ វិនិយោគ ខូ អិលធីឌី | កំពង់ធំ | 1,000 | 170 | 680 | 850 |
| 81 | សម្បត្តិ ផ្លេធីណឹម ខូ អិលធីឌី | កំពង់ធំ | 2,496 | 80 | 1,722 | 1,802 |
| 82 | ស៊ី អ ស៊ី ខេ  អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 5,272 | 555 | 4,017 | 4,572 |
| 83 | សាម ម៉េង អាហារ័ណ នីហារ័ណ | កំពង់ធំ | 225 | 150 | 45 | 195 |
| 84 | រតនៈខេម អាគ្រោ អ៊ិនដាសស្រ្ទៀល អិលធីឌី | កំពង់ធំ | 900 | 502 | 306 | 808 |
| 85 | ទ្រីភាព អ៊ីមផត អិចផត | កំពង់ធំ | 600 | 581 | | 581 |
| 86 | កុល វាសនា អិនវេសមេន ខូ អិលធីឌី | កំពង់ធំ | 6,198 | 30 | 1,490 | 1,520 |
| 87 | កៅស៊ូ មេកុង ខូ អិលធីឌី | កំពង់ធំ | 6,081 | 474 | 5,240 | 5,714 |
| 88 | សល សុភា ពាណិជ្ជ គ្រុប ខូ អិលធីឌី | កំពង់ធំ | 2,995 | | 200 | 200 |
| 89 | អាន ម៉ាឌី គ្រុប ខូ អិលធីឌី | កំពង់ធំ | 9,993 | | 800 | 800 |
| 90 | ប៉ោ ខួច អភិវឌ្ឍន៍ ខូ អិលធីឌី | កំពង់ធំ | 306 | | 10 | 10 |
| 91 | ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 8,553 | 4,400 | 3,836 | 8,236 |
| 92 | បៀន ហៀក អិនវេសមេន ខូ អិលធីឌី | កំពង់ធំ | 8,653 | 1,060 | 6,972 | 8,032 |
| 93 | រាម ណា វិនិយោគ ខូ អិលធីឌី | ព្រះវិហារ | 410 | | 27 | 27 |
| 94 | ធីង៉ា អភិវឌ្ឍន៍ និងវិនិយោគ ខូ អិលធីឌី | ព្រះវិហារ | 6,060 | 25 | 143 | 168 |
| 95 | ឫទ្ធី ក្រានីត (ខេមបូឌា) ខូ អិលធីឌី | ព្រះវិហារ | 1,646 | | 1,498 | 1,498 |
| 96 | ទ្រីភាព អ៊ីមផត អិចផត | ព្រះវិហារ | 4,800 | 518 | 2,954 | 3,472 |
| 97 | សុវណ្ណភូមិ វិនិយោគ កសិ-ឧស្សាហកម្ម | ព្រះវិហារ | 9,913 | | 2,700 | 2,700 |
| 98 | ខេមបូឌា ដោនផ្លេនថេសិន អិលធីឌី | ព្រះវិហារ | 9,237 | | 1,194 | 1,194 |
| 99 | ហ្គ្រីន ឌីវេឡុបមេន ខូ អិលធីឌី | ព្រះវិហារ | 984 | | 129 | 129 |
| 100 | មេត្រីភាព កសិ-ឧស្សាហកម្ម | ព្រះវិហារ | 8,520 | | 190 | 190 |
| 101 | សេហុង ផ្លេនថេសិន លីមីតធីត | ព្រះវិហារ | 9,700 | | 80 | 80 |
| 102 | សីលាដាម៉ិច ខូ អិលធីឌី | ព្រះវិហារ | 9,000 | | 490 | 490 |
| 103 | តៃនិញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | ឧត្តរមានជ័យ | 4,161 | | 3,834 | 3,834 |
| 104 | បេស រ៉ូយ៉ាល់ (ខេ) ខូ អិលធីឌី | ឧត្តរមានជ័យ | 3,943 | | 3,500 | 3,500 |
| 105 | សុខ សំណាង ឌីវេឡុបមេន ខូ អិលធីឌី | ឧត្តរមានជ័យ | 1,865 | | 975 | 975 |
| 106 | ដាតា រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ឧត្តរមានជ័យ | 7,700 | | 26 | 26 |
| 107 | ទុមរីង រ៉ាប់ប៊ើរ ខូ អិលធីឌី | ឧត្តរមានជ័យ | 7,750 | | 272 | 272 |
| 108 | ហួត ម៉េងរីតា ខូ អិលធីឌី | ឧត្តរមានជ័យ | 4,195 | | 1,360 | 1,360 |
| 109 | សំរោង រ៉ាប់ប៊ើរ អ៊ិនដាសស្រ្ទៀល ភី ធី អ៊ី អិលធីឌី | ឧត្តរមានជ័យ | 7,720 | 2,250 | 2,025 | 4,275 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ(ហិកតា) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| 110 | Green Rubber Development Plantation co.,LTD | សៀមរាប | 6,000 | | 641 | 641 |
| 111 | ខេន លីមីធីត | សៀមរាប | 4,535 | 620 | 1,171 | 1,791 |
| 112 | MDS (ទ្រី ភាព) | ពោធិ៍សាត់ | 6,352 | 300 | 2,700 | 3,000 |
| 113 | កោះកុង អេស អ៊ី ហ្សិត ខូ អិលធីឌី | កោះកុង | 4,100 | | 2,573 | 2,573 |
| 114 | កោះកុង រ៉ាប់បើរ ផ្លេនថេសិន ខូ អិលធីឌី | កោះកុង | 9,977 | | 1,474 | 1,474 |
| 115 | លឹម លុង ខូ អិលធីឌី (LIM LONG Co.,Ltd) | កោះកុង | 321 | 111 | 169 | 280 |
| II | **ចម្ការកៅស៊ូគ្រួសារ** | **ខេត្ត** | **0** | **119,837** | **41,266** | **161,103** |
